លេខ ១ ក304ក

# ទិព្វ

ទស្សនាវដ្ដីចេញរាល់ខែ

ខែកញ្ញា ឆ្នាំ១៩៥៦

ឆ្នាំទី ១

304

Rl 7-9-56.   ក 3045
P.K-17
1956-1

ឆ្នាំទី ១   លេខ ១   ខែកញ្ញា ១៩៥៦

# ទស្សនាវដ្ដី

## នៃសមាគមសាមគ្គីសិស្សចាស់នឹងមិត្តសិស្សចាស់

## នៃអនុវិទ្យាល័យ នឹង វិទ្យាល័យស៊ីសុវត្ថិ

ទីសំណាក់ការ លេខ ១៣០ វិថី ប៉ាស្ទ័រ ភ្នំពេញ

# មាតិការឿង


អារម្ភកថា .................................................... ទំព័រ ទី
សកម្មភាពសមាគម .................................................... ,, ,,
សន្ទរកថា .................................................... ,, ,,
ទំព័រអក្សរសាស្ត្រ (វិជ្ជា) .................................................... ,, ,,
បញ្ហាអនាម័យ (សុខភាព) .................................................... ,, ,,
រឿងកំសាន្ត .................................................... ,, ,,
សៀវភៅ .................................................... ,, ,,


## ដំឡៃជាវ

ក្នុងប្រទេស

| ១ ក្បាល | ៦ ខែ | ១ ឆ្នាំ |
|---|---|---|
| ១០រ | ៥០រ | ១០០រ |

ក្រៅប្រទេស

| ១ក្បាល | ៦ ខែ | ១ឆ្នាំ |
|---|---|---|
| ១៣រ | ៦០រ | ១២០រ |

សូមផ្ញើអាណត្តិទៅលោក សុភា-ភ្នុល លេខ១៣០វិថីប៉ាស្ទ័រ ភ្នំពេញ

# អារម្ភកថា

សមាគមសាមគ្គីសិស្សចាស់ និងមិត្តនៃអនុវិទ្យាល័យ និងវិទ្យាល័យស៊ីសុវត្ថិ មានសេចក្តីសោមនស្សជាក្រៃលែង ដោយជូនដល់សមាជិក និងអស់លោកអ្នកអានទាំងឡាយនូវទស្សនាវដ្តីនេះ ។ ទស្សនាវដ្តីនេះកើតឡើងដោយសារសេចក្តីព្យាយាម សេចក្តីមានៈនៃសមាជិកខ្លះ ដែលខំខ្នះខ្នែងជួយឧបត្ថម្ភដោយយោបល់ ដោយអត្ថបទ ។ ម្យ៉ាងទៀតការដែលទស្សនាវដ្តីនេះកើតឡើងសឲ្យឃើញថាចំណងរួម ដែលមានជាយូរមកហើយផុលផុសចេញប្រៀងជាការពិតឡើង ព្រោះតាំងពីពេលចំបាំងលើកទី២រួចមក គណកម្មាធិការនីមួយ ៗ តែងរិះគិត សមាជិកម្នាក់ ៗ តែងតែគិត តែងតែនឹកដល់ ព្រោះថាទស្សនាវដ្តីនេះ:

១– ជាចំណងមេត្រីភាពរវាងសមាជិកនិងសមាជិក រវាងសមាគមនិងសមាគម រវាងសមាគមនិងអគ្គការឯទៀត រវាងសមាគមនិងមហាជន និងវរជនទាំងឡាយ

២– បង្ហាញនូវសកម្មភាពនៃសមាគម

៣– ផ្សាយនិងពង្រីកនូវវប្បធម៌និងអារ្យធម៌ខ្មែរ (ការនេះជាគោលបំណងធំបំផុតរបស់សមាគម)

៤– ការពារផលប្រយោជន៍សមាជិកទាំងឡាយ ដែលជាផលប្រយោជន៍រួមរបស់សមាគម

៤-- ជាវេទិកាមួយសំរាប់ពិភាក្សារកខុសត្រូវក្នុងការរៀនសូត្រទូទៅ ។

តែតាំងពីក្រោយសង្គ្រាមលោកលើកទី២មក បំណងនេះពុំបានសំរេច ដោយមានឧបសគ្គច្រើន ឧបសគ្គអស់នោះមិនមែនត្រឹមតែរាំងរាមិនឲ្យដំណើរការនេះទៅមុខទេ ថែមទាំងធ្វើឲ្យសមាគមកាន់តែរួញទៅស្ទើររលាយបាត់តែម្តង ។ តែទុកជាយ៉ាងណាក៏ដោយក្នុងពេលនោះ សមាជិកយើងជាច្រើននៅតែខំខ្នះខ្នែងទ្រទ្រង់សមាគមយើងរហូតមកដល់ឥឡូវ ហើយចាប់តាំងពីស្រុកយើងបានឯករាជ្យមក សមាគមចាប់មានសកម្មភាពកាន់តែច្រើនឡើង តែសកម្មភាពនោះពុំទាន់បានពេញលេញទេ នៅខ្វះខាតជាច្រើន មកតែពីសមាគមដែលហៀបរលត់ទៅពុំទាន់មានកម្លាំងឲ្យដូចពីដើមវិញ ថវិកាខ្សត់ខ្សោយពេកពុំអាចឲ្យសមាគមធ្វើកិច្ចបាន ម្ល៉ោះហើយអ្នកដែលមិនមែនជាសមាជិកសឹងតែមិនដឹងថាសមាគមនេះមានឬគ្មានផង ។ ឯសមាជិកវិញ ដោយឃើញសមាគមគ្មានសកម្មភាពអ្វី ក៏កាន់តែរសេរសាស់អស់ដៃអស់ជើង ។ សរុបសេចក្តីទៅឃើញថា សមាជិកយើងច្រើនគ្នា មិនសូវដឹងនូវដំណើរនៃសមាគម ដោយឃើញថាសមាគមពុំដែលឲ្យផលប្រយោជន៍អ្វីដល់សោះ ។ បើយល់ដោយសើ ៗ ឃើញថាត្រូវដែររបៀបគិតយ៉ាងនេះ តែបើពិនិត្យឲ្យជ្រៅទៅ យើងនឹងឃើញថាដំណើរសមាគមនីមួយ ៗមកតែពីសមាជិកទាំងអស់គ្នាខំខ្នះខ្នែងប្រឹងប្រែងឡើង ជួយ

ឧបត្ថម្ភសមាគម ៗ សមាគមនឹងផ្តល់ផលប្រយោជន៍ឲ្យយើង លុះណាតែយើងឲ្យផលប្រយោជន៍ដល់សមាគម ៗ ម្យ៉ាងទៀតយើងគិតយល់ថា គណកម្មាធិការមិនអាចធ្វើតែឯងបានទេ គណកម្មាធិការមានយោបល់ខ្លះហើយ ក្នុងកិច្ចការនិមួយៗ តែនៅពុំទាន់គ្រប់គ្រាន់ទេ តែងតែខ្លះហើយអាចនឹងជួយពីប្រយោជន៍សមាជិកខ្លះផង ៗ

ដូច្នេះ ដើម្បីបំបាត់សភាពការខានលើនេះចេញ ដើម្បីនឹងឲ្យសមាគមដើរតាមគោលបំណងរបស់វា យើងត្រូវសាមគ្គីនឹងគ្នាឲ្យជិតស្និទ្ធ គឺសាមគ្គីរវាងសមាជិក នឹងសមាជិក រវាងសមាជិកនឹងគណៈកម្មាធិការ ដើម្បីនឹងជួយមើលជួយពិនិត្យគណៈកម្មាធិការ ជួយយោបល់ ជួយមតិៗ មានតែរបៀបនេះទេដែលធ្វើឲ្យសមាគមយើងដើរតាមគោលបំណងបាន ៗ

សរុបសេចក្តីទាំងអស់ យើងសន្និដ្ឋានបានថា ទស្សនាវដ្តីយើងនេះ នឹងរស់បានលុះណាតែយើងទាំងអស់គ្នាជួយ គឺថាយើងមិនត្រូវគ្រាន់តែមើលហើយចោលនោះទេ យើងត្រូវមើលហើយពិចារណា មើលហើយធ្វើទិទៀន មើលហើយឲ្យយោបល់ តើវាខ្វះឬវាលើស ? ល្មមឬមិនល្មម ? តោងតែយើងមើលឲ្យគ្រប់ ពេលនោះហើយ ទើបទស្សនាវដ្តីយើងដើរទៅមុខ ទើបសមាគមយើងនេះចំរើនបាន ៗ យើងខ្ញុំសូមជំរាបជាមុនថា ទស្សនាវដ្តីនេះមិនមែនរបស់គណៈ

គម្មាធិការឬរបស់អ្នកឯណាមួយ ទស្សនាវដ្ដីនេះជារបស់រួមជារបស់សមាគមទាំងមូល ហេតុដូច្នោះយើងខ្ញុំសូមបញ្ជាក់ថា អ្នកណាក៏មានសិទ្ធិសរសេរអត្ថបទដើម្បីឲ្យយើងចុះផ្សាយ តែគណៈកម្មាធិការសូមទុកសិទ្ធិពិនិត្យនិងអារកាត់ចំពោះអត្ថបទណាដែលមិនស្របទៅតាមគោលបំណងរបស់សមាគម ដែលបានចែងទុកយ៉ាងច្បាស់នៅក្នុងលក្ខន្តិក ម្យ៉ាងទៀតយើងទុកសិទ្ធិនោះដោយសារតែសមាគមទាំងមូលទទួលការខុសត្រូវលើអត្ថបទដែលផ្សាយនៅក្នុងទស្សនាវដ្ដីនេះ ។ ចំពោះខ្លឹមសារអត្ថបទវិញ យើងខ្ញុំចង់បានតែអត្ថបទណាដែលជាការអប់រំ ជាដំរេះខួរទៅ ចង់ជារឿងក្ដី ចង់ជាមេរៀនក្ដី តែសូមកុំឲ្យវែងពេក គឺថាធ្វើម្ដេចកុំឲ្យមានត ព្រោះថាតាមការសង្កេតរបស់យើងទៅឃើញថាទស្សនាវដ្ដីចេញមួយខែម្ដងធ្វើឲ្យអ្នកអានធុញទ្រាន់ចាំអានរឿងដែលមានតទៅទៀត ។ ដោយសេចក្ដីសង្ខេបយើងខ្ញុំជាគណៈកម្មាធិការសូមផ្ញើសេចក្ដីសង្ឃឹមលើអ្នកអានទាំងឡាយមានសិស្សានុសិស្សនិងនិស្សិតជាដើម ដើម្បីជួយជម្រុញ ជួយទិទៀន ជួយយោបល់ ជួយផ្ដល់នូវអត្ថបទ សរុបទៅគឺថាជួយធ្វើឲ្យទស្សនាវដ្ដីនេះទៅជាទស្សនាវដ្ដីរបស់សមាគមពិតប្រាកដ ។

គណកម្មាធិការនាយក

X

X X

# សកម្មភាពសមាគម

ទី១– មហាសន្និបាត ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ១៩៥៦

ក្រោមចំណងជើងនេះ យើងសូមស្រង់សេចក្ដីសំរេចរបស់មហាសន្និបាតខ្លះ ។

នៅថ្ងៃទី៣ កុម្ភ ឆ្នាំ ១៩៥៦ សមាគមសាមគ្គីសិស្សចាស់នឹងមិត្តនៃអនុ-វិទ្យាល័យនឹងវិទ្យាល័យស៊ីសុវត្ថិបានធ្វើមហាសន្និបាតប្រចាំឆ្នាំនៅទីសំណាក់ការរបស់សមាគម នៅវេលាម៉ោង ២០ ។

របៀបវារៈ:

១– សេចក្ដីរាយការណ៍របស់ប្រធានសមាគម

២– សេចក្ដីរាយការណ៍របស់ហេរញ្ញិក

៣– ការលាឈប់នៃគណៈកម្មាធិការនាយកចាស់ ការពិភាក្សានឹងការរើសគណៈកម្មាធិការថ្មី ។

– សេចក្ដីរាយការរបស់ប្រធានសមាគម.– ក្រោមអធិបតីភាពនៃលោក អ៊ុក-ឆុប មហាសន្និបាតក៏បានបើកសម័យប្រជុំតាមរបៀបវារៈខាងលើនេះៗ តាមសេចក្ដីរាយការណ៍របស់ប្រធាន សាន់គឿន យើងសូមដកស្រង់ដូចតទៅ៖

«ដោយសមាគមពុំសូវមានសកម្មភាពប៉ុន្មាន គណៈកម្មាធិការនាយកមានបំណងនឹងធ្វើសកម្មភាពឲ្យមានគ្រប់គ្រាន់ឡើងដូចខាងសង្គមកិច្ច ខាងវប្បធម៌ ខាងកីឡា ។ល។ តែដោយខ្វះថវិកា គ្រោងការនោះបានសម្រេចតែផ្នែកខ្លះដូចខាងក្រោមនេះ៖

– ជួយដល់សិស្សទីទាល់ក្រពីរនាក់ដែលមានជម្ងឺ

– ឲ្យប្រាក់ខ្ចីចំនួន១.០០០រៀលម្នាក់ ១ ដល់និស្សិត១០នាក់ ដែលចេញទៅបន្តវិជ្ជានៅប្រទេសក្រៅ

– ធ្វើសន្និសិទបាន២ដង

– ធ្វើពត៌សមោសរមួយ

– ជួសជុលទីសំណាក់ការសមាគម

សព្វថ្ងៃមានសមាគមបរទេសខ្លះគេចង់ទាក់ទងនឹងយើងដែរ តែដោយពេលវេលាខ្វះពេក យើងក៏ពុំទាន់បានធ្វើយ ។

២– សេចក្ដីរាយការណ៍របស់ហេរញ្ញិក – បន្ទាប់មកលោក យស់·

មាន ហេរញ្ញិក ប្អូនធ្វើសេចក្តីរាយការណ៍ពីស្ថានការណ៍ហេរញ្ញវត្ថុដូចតទៅ :

| ចំណូល | ចំណាយ |
|---|---|
| ឈ្នួលផ្ទះ - - - ៩.៦២០;០០ | ប្រាក់ខែបុង្គុន...៩០០០;០០ |
| ពក្រ៊ីសមោស..៧.៩៧៥;០០ | ទឹកនឹងភ្លើង.....៧៩៤;៣៤ |
| ការរៃប្រាក់...២៣.៦០៦;០០ | ប្រដាប់ប្រដាការិយាល័យ ៨៣៧;០៥ |
| សំណងប្រាក់ដែលឲ្យខ្ចី១១០០;០០ | ការជួសជុលដល់ទីសំណាក់ការ ៩.២៥៨;០០ |
| ប្រាក់គង់ហិប..៣.៣៧៥;៩៤ | ចំណាយផ្សេងៗ...៤.៤២៤ |
| | ជំនួយដល់សិស្សមានជម្ងឺ ២ នាក់ ៦០០;០០ |
| | ឲ្យនិស្សិតខ្ចី(១០នាក់)១០.០០០;០០ |
| បូករួម ៤៥.៦៧៦;៩៤ | បូករួម ៣៤.៩៣៣;៣៧ |

ចំណូល ៤៥.៦៧៦;៩៤ – ៣៤.៩៣៣;៣៧ = ១០.៧៤៣;៤៧

ប្រៀបធៀបឆ្នាំចាស់នឹងឆ្នាំថ្មី

| | ឆ្នាំ១៩៥៤ | ឆ្នាំ១៩៥៥ |
|---|---|---|
| ប្រាក់ឲ្យខ្ចីពីមុនមក | - - - ២៧.៤៧០;០០ | ៣៧.៤៧០;០០ |

នៅឃ្លាំង - - - ១៣.៨៨៧៛០០    ១៩.៨៨៧៛០០

សល់ក្នុងហិប - - ៣.៣៧៥៛៨៤    ៤.៧៤៣៛៤៧

បូករួម ៤៤.៧៣២៛៨៤    ៦២.១០០៛៤៧

កើនក្នុងឆ្នាំ១៩៥៥ ៦២.១០០៛៤៧–៤៤.៧៣២៛៨៤=១៧.១០០៛៤៧

**៣.– ការលាឈប់នៃគណៈកម្មាធិការនាយកចាស់និងការរើស គណៈកម្មាធិការនាយកថ្មី.–** តពីសេចក្តីរាយការណ៍របស់ហេរញ្ញិកមក គណៈកម្មាធិការចាស់ក៏បានលាឈប់ពីតំណែង ៗ ដោយយល់ឃើញថាចំនួន សមាជិកគណៈកម្មាធិការនាយកច្រើនពេក មហាសន្និបាតបានសំរេចបន្ថយចំនួន សមាជិកគណៈកម្មាធិការនាយកពី ១៤ នាក់ មកនៅតែ ១០ នាក់ រួមទាំងប្រធាន ផង ៗ រួចពីនោះមកមហាសន្និបាតក៏ជ្រើសតាំងគណៈកម្មាធិការនាយកថ្មីតាម វិធីបោះឆ្នោតសម្ងាត់ លទ្ធផលបានដូចខាងក្រោមនេះ ៖

| | | |
|---|---|---|
| ប្រធាន | លោក | សាន់ - អឿន |
| អនុប្រធាន | — | ផែង - កន្ទួល |
| អគ្គលេខាធិការ | — | អ៊ុល - បុន |
| លេខាធិការរង | — | សរ គិម លុត |
| ហេរញ្ញិក | — | លី គិម គិម |

ហេរញ្ញិករង — យស - ម៉ាន់

បណ្ណារក្ស — សុក - គុណ

បណ្ណារក្ស — សុក - សុនកែវ

ស្នងការ — កែវ - ម៉ុងគ្រី

ស្នងការ — ជុំ - ចាន់សុទ្ធី

ក្រោយពីការរើសគណៈកម្មាធិការរួច មហាសន្និបាតក៏បានបិទសម័យប្រជុំនៅវេលាម៉ោង ២៣ ។

ទី២ បុណ្យចូលឆ្នាំ .— ក្នុងឱកាសបុណ្យចូលឆ្នាំកែនេះ សមាគមយើងបានរៀបពិធីជុំបលៀងមួយ នៅទីសំណាក់ការសមាគម កាលពី ខែមេសាឆ្នាំ១៩៥៦ ។ សមាគមបានអញ្ជើញក្រៅពីសមាជិកនៃសមាគម នូវឯកជនជាច្រើននាក់ ហើយថែមទាំងអញ្ជើញតំណាងសារពត៌មានខ្មែរគ្រប់សារពត៌មាន ហើយនឹងតំណាងសារពត៌មានបារាំងមួយគឺ «រេអាលីតេ» ។ ពិធីបុណ្យបានចាប់ផ្ដើមធ្វើនៅវេលាម៉ោង១៨កន្លះ ។ លោកប្រធានមុនចាប់ធ្វើសុន្ទរកថាបានអញ្ជើញលោករឹម-គិនមកអធិប្បាយពីអត្ថរសនឹងអត្ថន័យ នៃបុណ្យចូលឆ្នាំនៅស្រុកខ្មែរ ។

លោករឹម-គិនបានអធិប្បាយដ៏ក្បោះក្បាយ អំពីបុណ្យចូលឆ្នាំនៅស្រុកខ្មែរជូន

សមាជិកទាំងក្មេងទាំងឡាយដែលចូលមកប្រជុំប្រាស្រ័យនៅវេលាបុណ្យនោះ ។

រួចមកលោកប្រធានក៏បានថ្លែងអំណរគុណ ដល់លោកមេះ-គិនដល់មិត្តទាំងឡាយដែលបានមកជួបជុំ រួចក៏លោកបានអធិប្បាយដោយសង្ខេបនូវប្រវត្តិនៃសមាគម ហើយនឹងបុព្វហេតុដែលនាំឲ្យសមាគមធ្វើពិធីបុណ្យនេះ ។

១– សមាគមចង់លើកដំកើងនូវអារ្យធម៌ខ្មែរ គឺចង់ឲ្យខ្មែរ ៗ បានស្គាល់នូវអត្ថន័យនៃបុណ្យនេះ ។

២– សមាគមមានបំណងនឹងពង្រីកខ្សែមេត្រីភាព ឲ្យបានឆ្ងាយទូលាយពីរង្វង់សមាគម (ដូចជាបានអញ្ជើញដំណាងសារពត៌មាន-តំណាងសមាគមខ្លះ)

រួចពីនេះទៅ ការជប់លៀងក៏បានផ្ដើមឡើងក្នុងបរិយាកាសដ៏រីករាយ ។ សមាជិកទាំងក្មេងបានជជែកគ្នាដោយយ៉ាងជិតស្និទ្ធ ៗ យូរៗគេឃើញមានអ្នកកំប្លែងដើរពីហ្វូងមួយទៅហ្វូងមួយ បណ្ដាលឲ្យឮសូរសំណើចយ៉ាងក្អាកក្អាយម្ដង ៗ ។

ក្នុងពេលនោះ គេមានសេចក្ដីស្ដាយមួយ គឺស្ដាយថាគ្មានភ្លេងជួយជទ្រី តែការនេះមិនមកពីអ្វីទេ គឺមកពីសមាជិកយើងមិនសូវចេះភ្លេង ឬបើចេះវិញក៏មិនដែលលេងជាមួយគ្នា ។ បើនឹងជួលភ្លេងគេមកលេងក៏បានដែរ តែធ្វើដូច្នោះដូចជាពុំសូវសប្បាយ ពុំសូវជិតស្និទ្ធ ។

ប្រហែលជាម៉ោង ២១ យប់ណាស់ហើយ គេក៏បែកគ្នាដោយ

ជាប់ចិត្តជាក្រៃលែងនឹងពាក្យនេះ ។

## ទី៣.– ភេសជ្ជៈកិត្តិយសដល់និស្សិត

តាមប្រពៃណីរបស់សមាគម ហើយជាកិត្តិយសដល់និស្សិតដែលបំរុងចេញទៅបន្តវិជ្ជានៅប្រទេសក្រៅ ហើយនឹងនិស្សិតដែលទើបត្រឡប់ចូលមកប្រទេសខ្មែរវិញក្នុងឆ្នាំ ១៩៥៦ នេះ សមាគមយើងបានធ្វើពិធីលៀងភេសជ្ជៈមួយ ពីថ្ងៃ៩ ខែសីហា ឆ្នាំ១៩៥៦នៅទីស្នាក់ការសមាគម ។

ក្នុងពិធីបុណ្យនេះ គេសង្កេតឃើញមានសមាជិកជាច្រើនរូប បានមកជួបជុំគ្នាក្នុងបរិយាកាសដ៏ស្និទ្ធស្នាល ។

នៅម៉ោង ១៨ កន្លះ ដោយគ្មានភ្ញៀវអញ្ជើញមកទៀតទេ លោកប្រធានក៏បានបើកពិធីបុណ្យនេះដោយថ្លែងសុន្ទរកថាមួយ ពន្យល់ពីអត្ថន័យនឹងគោលបំណងនៃបុណ្យនេះ តែលោកសង្កត់ខ្លាំងទៅលើធម៌សាមគ្គីដើម្បីកសាងសាមគ្គីរវាងសិស្ស-រវាងនិស្សិត សាមគ្គីរវាងសមាជិក សាមគ្គីរវាងពលរដ្ឋ ។

រួចមកលោក ផែន-កន្ទុល អនុប្រធានបានអានឈ្មោះនិស្សិត ៣២ នាក់ដែលទើបនឹងត្រឡប់មកក្នុងឆ្នាំនេះ នឹងឈ្មោះនិស្សិត១៥រូបទៀតដែលបំរុងនឹងចេញទៅបន្តវិជ្ជានៅប្រទេសក្រៅ ។

បន្តពីសុន្ទរកថាលោកប្រធាន បំពោះបំណុបសាមគ្គីធម៌-ឯកឧត្តមសម-

សារី  បានថ្លែងសន្ទកថាមួយពន្យល់យើងពីស្ថានភាពនយោបាយនៅក្នុងស្រុកខ្មែរ ហើយនឹងនយោបាយស្វែងរកសាមគ្គីរបស់សង្គមរាស្ត្រនិយម  ដើម្បីកសាងប្រទេស ។

ក្រោយពីឯកឧត្តមសម-សារី មក លោក ហ៊ូ-យន់ ដែលជានិស្សិតមួយទើបនឹងត្រឡប់មកពីប្រទេសបារាំង  បានឡើងថ្លែងសន្ទកថាមួយផ្ដោះទៅកាន់និស្សិតដែលបំរុងនឹងចេញទៅប្រទេសក្រៅ ។  ក្នុងបញ្ហាបែកបាក់សាមគ្គីរវាងនិស្សិត លោកពន្យល់ថា «បើសិនជានិស្សិតទាំងនោះ  មានយោបល់ប្លែកគ្នាក្នុងគំនិតអ្វីមួយក៏ដោយ  តែយើងអាចរក្សាសាមគ្គីបានវិញ  ដោយនិយមគ្នានៅលើចំណុចណាមួយដ៏ជាក់លាក់ដោយសំអាងទៅលើផលប្រយោជន៍រួម» ។

បន្ទាប់មកលោកហ៊ីង-កន្ធែល  ដែលជានិស្សិតទើបនឹងត្រឡប់មកដែរ ក៏បានធ្វើអត្ថាធិប្បាយលើសាមគ្គីនេះដែរ ។

ដោយពេលយប់កាន់តែទន្ទ្រានមកហើយ លោកប្រធាន ក្រោយដែលបានថ្លែងអំណរគុណដល់អស់លោកទាំងបីរូបដែលមានប្រសាសន៍បន្ត ១ គ្នា  ក៏សូមអញ្ជើញសមាជិកទាំងភ្ញៀវទាំងអស់  ឲ្យពិសាភេសជ្ជៈ  ដែលមានឱជារសឆ្ងាញ់ពិសា ។ យើងសង្កេតឃើញបរិយាកាសមួយល្អប្លែកគួរកត់ទុកក្នុងប្រវត្តិសាស្ត្រសមាគមសាមគ្គីសិស្សចាស់និស្សិតចាស់នឹងថ្មីដែលមានភាគច្រើនជាងគេសំណេះ

សំណាលគ្នា និយាយអំពីអនុស្សាវរីយ៍ផ្សេងៗ ។

យើងឆ្លៀតឱកាសនេះដើម្បីនឹងសំដែងសេចក្ដីសរសើរដល់លោកចាស់ៗ ដែលជាសមាជិកសមាគម «ជើងចាស់» ដូចជាលោកប៉ាច-ឈឺន លោកអ៊ុក-ឌុប លោកតាជាវលីជាដើម ដែលអញ្ជើញមកជួបជុំសមាគមក្នុងពិធីបុណ្យធំៗ មិនដែលខកខានឡើយ ។

នៅម៉ោង២១ យប់កាន់តែជ្រៅណាស់ហើយៗ ស្អែកឡើងជាថ្ងៃធ្វើការផង អស់ភ្ញៀវនឹងសមាជិកទាំងឡាយក៏លាគ្នាទៅកាន់គេហដ្ឋានវិញ យ៉ាងសោកស្ដាយនឹង«រាត្រីសាមគ្គីភាព» ហើយសង្ឃឹមថានឹងបានជួបជុំគ្នាទៀតនៅពេលឆាប់ៗនេះ ។

---

## ដំណឹងផ្សេងៗ

សមាគមមានសេចក្ដីត្រេកអរនឹងទទួលអំណោយ អង្គុលីលេខខ្មែរមួយពីលោកឈាន-វម ។

សូមលោកឈាន-វមទទួលអំណរគុណដ៏ជ្រាលជ្រៅអំពីសមាគម ។

X X
X

# សុន្ទរកថា

យើងខ្ញុំសូមចុះផ្សាយទាំងស្រុងក្នុងទស្សនាវដ្ដីនេះ សន្ទរកថានៃលោកសាន់-អៀន ថ្លែងក្នុងពិធីជប់លៀងភេសជ្ជៈនៅថ្ងៃ ៩ សីហា ១៩៥៦ ជាកិត្តិយសដល់និស្សិតដែលទៅបន្តវិជ្ជានៅបរទេស និងដល់និស្សិតដែលត្រឡប់មកប្រទេសវិញក្នុងឆ្នាំ១៩៥៦ ។

## ឯកឧត្ដម - អស់លោក - មិត្តទាំងឡាយ

ដើម្បីជាកិត្តិយសដល់និស្សិតដែលនឹងទៅបន្តវិជ្ជានៅប្រទេសក្រៅ និងដល់និស្សិតដែលទើបនឹងត្រឡប់ចូលមកប្រទេសខ្មែរវិញ សមាគមយើងបានរៀបលៀងភេសជ្ជៈជារាល់ឆ្នាំ ៗ ការលៀងភេសជ្ជៈនេះវាទៅជាប្រពៃណីរបស់សមាគមមួយ ដូច្នោះឆ្នាំនេះក៏ដូចឆ្នាំមុន ៗ សមាគមយើងបានប្រមូលផ្ដុំសមាជិក អញ្ជើញនិស្សិតមកធ្វើពិធីលៀងនេះ ។

---

ក្នុងនាមនៃសមាគម ខ្ញុំសូមថ្លែងនូវសេចក្ដីសោមនស្សដ៏ជ្រាលជ្រៅចំពោះអស់លោកនិងមិត្តទាំងឡាយ ដែលបានមកជួបជុំក្នុងពេលនេះ ។ ក្នុងការជួបលៀងនេះ សមាគមគ្មានបំណងអ្វីក្រៅពីការសំដែងនូវសេចក្ដីត្រេកអរដល់និស្សិតដែលមានភព្វសំណាងទៅបន្តវិជ្ជាទៀតនៅប្រទេសក្រៅ និងជូនពរដល់និស្សិតដែលទើបនឹងត្រឡប់ចូលមកប្រទេសវិញដោយសង្ឃឹមយ៉ាងមាំថានិស្សិតអស់នោះនឹងនាំការពិសោធមកជួយកសាងប្រទេស ពិសេសជួយកសាងសមាគមយើងនេះឲ្យមានបុគ្គលាប់ថែមទៀត ។ សមាគមមានបំណងមួយទៀត បំណង

ដែលធំជាងគេគឺបំណងតែបំណងមេត្រីភាព បំណងសាមគ្គីរវាងសមាជិក រវាងនិស្សិត សរុបទៅសាមគ្គីរវាងខ្មែរទាំងមូល ។

យើងតែបំណងសាមគ្គីនេះដើម្បីៈ

ទី ១ — កសាងខ្លួនយើង-យើងយល់ច្បាស់ថា ក្នុងការរស់នៅរាល់ថ្ងៃ យើងមិនអាចរស់នៅដោយឯកឯងបានទេ យើងត្រូវការទាក់ទងអ្នកក្រៅដទៃទៀតយើងជានិច្ច ព្រោះការរស់នៅរបស់យើងជាការរស់នៅដោយពួក ដោយសង្គម ។ ក្នុងកិច្ចការដែលយើងធ្វើរាល់ថ្ងៃ យើងមិនអាចធ្វើតែឯងបានទេ បើយើងចង់ចំរើន យើងត្រូវអាស្រ័យគ្នាទៅវិញទៅមក ។ ការទាក់ទងរវាងគ្នាផ្អែកទៅលើស្មារតីសាមគ្គីធម៌ជាធំ បើគ្មានសាមគ្គីធម៌ទេ កិច្ចការដែលយើងធ្វើវាមិនកើត ឧទាហរណ៍ដូចអ្នករៀនសូត្រ បើគ្មានសាមគ្គីរវាងសិស្សនឹងសិស្សទេ ការរៀនសូត្រពុំសូវបានលូតលាស់ទេ បើគ្មានសាមគ្គីរវាងគ្រូនឹងសិស្សទេ ការរៀនសូត្រក៏ឱនថយគឺមិនចំរើន ។

ទី ២ — យើងសាមគ្គី ដើម្បីកសាងប្រទេស ក្នុង « ខ » នេះ ខ្ញុំមិននិយាយឲ្យវែងទេ ពីព្រោះវាមិនមែនជានាទីរបស់សមាគមយើងទេ ខ្ញុំគ្រាន់តែរំឭកប៉ុណ្ណោះ នគរយើងដែលអាប់ឱនទៅជិត១០០ឆ្នាំមក ក៏មកពីការគ្មានសាមគ្គីធម៌រវាងប្រជាជន ហើយដែលស្រុកយើងបានថ្កុំថ្កើងរុងរឿងសព្វថ្ងៃនេះ

ក៏អាស្រ័យលើសាមគ្គីធម៌រវាងប្រជាជនគ្រប់ជាន់ថ្នាក់ ដោយសង្ខេបយើងឃើញថា ខ្មែរបែកសាមគ្គីខ្មែរខ្ញុំគេ រួមសាមគ្គីខ្មែររុងរឿងថ្កុំថ្កើង ៗ ក្នុងពេលនេះ ខ្ញុំសូមនិយាយពីសាមគ្គីក្នុងសមាគមវិញ គឺសាមគ្គីដើម្បីកសាងសមាគមយើង សមាគមយើងនេះកើតឡើងអាស្រ័យលើសាមគ្គីធម៌នៃសមាជិកមួយផ្នែកធំ ៗ សមាគមយើងនេះ មានគោលបំណងមួយល្អណាស់ គឺប្រមូលវរៈជនក្នុងប្រទេសខ្មែរទាំងមូលមិនប្រកាន់ដល់បក្សពួក ដល់នយោបាយ ដល់សាសនា សមាគមនេះវាជាកន្លែងប្រមូលផ្តុំមួយដើម្បីកសាងវប្បធម៌ ពង្រីកនូវអារ្យធម៌ខ្មែរ ៗ តែការកសាងនេះទៀត វាអាស្រ័យទៅលើធម៌សាមគ្គីដដែល ព្រោះថាបើគ្មានធម៌សាមគ្គីហើយ សមាជិកម្នាក់ៗ មិនអាចធ្វើឲ្យសមាគមចំរើនបានឡើយ ៗ ដូច្នោះគេឃើញថា បើសមាជិកម្នាក់ ៗ មិនសូវរវល់គិតដល់សមាគមទេ ឃើញថាសកម្មភាពសមាគមរួញក្រិន ៗ ដោយគ្មានការជិតស្និទ្ធនេះហើយ យើងមានឃើញការម៉្យាងទៀត សមាជិកខ្លះ ក្រៅពីបង់ភាគទានរាល់ខែ មិនដែលឃើញមកអើតមុខក្នុងការប្រជុំអ្វីមួយ ៗ របស់សមាគមទាល់តែសោះ ៗ

ដោយយល់ឃើញអំពីការអន្តរាយដែលមកពីគ្មានធម៌សាមគ្គី សមាគមយើងសង្ឃឹមយ៉ាងមាំថា និស្សិតដែលទើបនឹងត្រឡប់មកដល់ស្រុកខ្មែរវិញ មិនព្រងើយកន្តើយនឹងសមាគមយើងឡើយ មុខតែមកជួយរួបរួមក្នុងសមាគមយើង

នេះ ដើម្បីនឹងធ្វើឲ្យសមាគមនេះលូតលាស់ឡើង ។

ចំណែកនិស្សិតដែលបំរុងនឹងចេញទៅបន្តវិជ្ជានៅប្រទេសក្រៅ ហើយដែលជាពុំទាន់ជាសមាជិកនៃសមាគមនៅឡើយ សមាគមមានសង្ឃឹមយ៉ាងមាំថាអ្នកនឹងរួបរួមសាមគ្គីរវាងគ្នានឹងគ្នា រវាងអ្នកនឹងប្រជាជនស្រុកដែលអ្នកទៅនៅដើម្បីពង្រីក ដើម្បីផ្សាយនូវអារ្យធម៌ខ្មែរ ហើយក្រេបជញ្ជក់នូវអារ្យធម៌គេដើម្បីកែដំរង់ដើម្បីធ្វើឲ្យចំរើនដល់អារ្យធម៌យើង ។ ពិតមែនតែអ្នកពុំទាន់ជាសមាជិកនៃសមាគមយើងនៅឡើយ តែអ្នកត្រូវធ្វើការនេះ ព្រោះការនេះជាបំណងរបស់ប្រជាជនខ្មែរទាំងមូល ។ ម្យ៉ាងទៀតដើម្បីនឹងកសាងខ្លួនអ្នកក៏ដូចជាកសាងប្រទេស ចូរអ្នកពិនិត្យពិចារណា ក្រេបយកវិជ្ជាណាដែលមានផលប្រយោជន៍ដល់យើងជៀស វាងដំនេះណា ដែលប្រើក្នុងស្រុកយើងមិនកើត ។

ខ្ញុំសូមសង្ខេបតែប៉ុណ្ណេះ តែមុននឹងអញ្ជើញពិសារលៀង ចំពោះនិស្សិតដែលទើបត្រឡប់មកក៏ដូចនិស្សិតដែលបំរុងនឹងចេញទៅ សមាគមសូមជូនពរឲ្យអ្នកបានជ័យជំនះក្នុងការតស៊ូយកដំនេះ ជ័យជំនះក្នុងការបំរើប្រជាជន កសាងឯករាជ្យ-សន្តិភាព ។

X X X

X X X

# ទំព័រទស្សនសាស្ត្រ

## វិជ្ជា

វិជ្ជាគឺអ្វីដែលឲ្យយើងចេះដឹងអំពីមនុស្ស ( ខ្លួនយើងក្តី អ្នកដទៃក្តី ) ចេះដឹងអំពីមជ្ឈដ្ឋានដែលមនុស្សជ្រលក់ខ្លួននៅក្នុងនោះ ចេះដឹងអំពីការទាក់ទងរវាងមនុស្សនឹងមជ្ឈដ្ឋាននោះ នឹងរវាងមនុស្សនឹងមនុស្ស ហើយចេះប្រើការចេះដឹងនោះមកជាប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃ ដែលខ្លួនរស់នៅជាមួយផង ។

បើគិតតែត្រឹមបច្ចុប្បន្នសម័យនេះ វិជ្ជាដែលគ្រប់ភាសាប្រទេសនិយមបណ្តុះឲ្យកុលបុត្រកុលធីតាគេតាំងពីសាលាតូចដល់សាលាធំបំផុត តាមលំដាប់ពីស្រាលទៅពិបាក គឺវិជ្ជាអក្សរ ឬ អក្សរសាស្ត្រ វិជ្ជាលេខ ឬ គណិតសាស្ត្រ ប្រវត្តិសាស្ត្រ ឬវិជ្ជាឲ្យចេះដឹងអំពីការរស់នៅនឹងរបៀបរស់នៅរបស់មនុស្សតាមជំនាន់តាមសម័យ ភូមិសាស្ត្រ ឬ វិជ្ជាឲ្យស្គាល់នូវភាពផែនដីនឹងជីវិតមនុស្សក្នុងបច្ចុប្បន្នសម័យ ទស្សនៈវិជ្ជា ឬ វិជ្ជាឲ្យពិចារណាឆ្លុះមើលអំពីកំណើតមនុស្ស អំពីការវិវត្តន៍ផ្លាស់ប្តូរដែលកើតមានក្នុងគំនិតប្រាជ្ញារបស់មនុស្ស វិទ្យាសាស្ត្រ

ឬវិជ្ជាឲ្យស្គាល់នូវជាតិកំណើត ដំណើរជីវិត សកម្មភាពផ្សេងៗនៃទឹកដី មេឃ ដើមឈើ សត្វផងទាំងឡាយ នឹងមនុស្សផង ។ ក្រៅពីនេះទៀតមាន វិជ្ជាខាងកសិកម្ម ឬការធ្វើស្រែចំការដាំដំណាំ វិជ្ជាខាងឧស្សាហកម្ម ឬការធ្វើគ្រឿងចក្រនឹងកែប្រែវត្ថុធម្មជាតិឬវត្ថុដើម ឲ្យទៅជាវត្ថុហើយស្រេចអាចប្រើការទៅផ្សេងៗ ដូចជាការធ្វើក្រដាស ត្បាញសំពត់សូត ។ ល ។ វិជ្ជាពាណិជ្ជកម្ម ឬវិជ្ជាខាងជំនួញលក់ដូរជួញប្រែ ។

តទៅទៀតមានវិជ្ជាខាងសិល្បៈ គំនូរ ចម្លាក់ សំណង់ ភ្លេង ចំរៀង ល្ខោន កំណាព្យកាព្យឃ្លោង ។ មានវិជ្ជាខាងកីឡា គឺការហាត់ប្រាណតាមក្បួនខ្នាត លេងល្បែងបាល់ លោត រត់ ហែលទឹក ។ ល ។ រហូតដល់ទៅវិជ្ជាខាងផ្ទះសម្បែងសំរាប់នារីផង ។ ខ្ពស់ហួសនេះទៅទៀត ហើយគ្របពីលើវិជ្ជាឯទៀតទាំងអស់ គឺវិជ្ជាដឹកនាំនឹងរៀបចំស្រុកទេស ដែលគេហៅថាវិជ្ជាខាងនយោបាយ ។ ដឹកនាំនឹងរៀបចំខាងក្នុងស្រុកឬនយោបាយក្នុងប្រទេស ដឹកនាំនឹងរៀបចំឲ្យមានការទាក់ទងគ្រប់បែបយ៉ាង ជាមួយប្រទេសដទៃ ឬនយោបាយក្រៅប្រទេស ។

វិជ្ជាសព្វគ្រប់ទាំងនេះ បណ្ដុះគំនិតប្រាជ្ញា បណ្ដុះចិត្តនឹងបណ្ដុះកាយ ។ នៅតាមប្រទេសគេមានសាលាបង្ហាត់សព្វវិជ្ជាទាំងនេះ តាំងពីវិជ្ជាឆាយ ដូចជាការរៀប

បំផុះសម្បូរជាដើម ដោយប្រើក្បួនខ្នាតវិន័យយ៉ាងហ្មត់ចត់-រហូតដល់វិជ្ជាពីបាក បំផុតៗយ៉ាងនេះហើយបានជានៅស្រុកគេ មានអ្នកនិពន្ធបណ្ឌិត អ្នកប្រាជ្ញសាស្ត្រ ចំណាន មានកសិករ ឧស្សាហករ ពាណិជករ វិស្វករ យ៉ាងជំនាញ គេមាន ជាងគំនូរ ជាងចម្លាក់ អ្នកសង់គេហស្ថាន អ្នកភ្លេង អ្នកច្រៀង អ្នកពិណពាទ្យ មានអ្នកកីឡាស្ទាត់ជំនាញ មានមេផ្ទះប៉ិនប្រសប់ មានអ្នកនយោបាយពូកែការពារ ផលប្រយោជន៍ឲ្យប្រទេសជាតិមាតុភូមិគេ ៗ

អាស្រ័យវិជ្ជានេះហើយ ទើបប្រទេសនីមួយ ៗ ចាកផុតពីសេចក្ដីល្ងង់ខ្លៅ ក្រ ខ្សត់ ឆ្ពោះទៅរកសេចក្ដីចំរើនរុងរឿងរៀង ៗ ហេតុមកអំពីសេចក្ដីចំរើនរុងរឿង នៃវិជ្ជានេះហើយ បានជាទៅក្នុងសកលលោកទាំងមូល តាំងពីមហានគរចូលដល់ ស្រុកតូចតាច ហើយជាពិសេសស្រុកតូចតាចដែលបានភ្ញាក់រឭក រើបម្រះចេញ រួចពីទ្រូងដែកចក្រពត្តិ ណានិគមនិយម គេមានបេតនាស្មុះយ៉ាងខ្លាំងទៅរក វិជ្ជា ៗ ដូចយ៉ាងស្រុកខ្មែរយើងនេះជាកស្តុតាងស្រាប់ យើងក៏ឃើញច្បាប់នីងក្នុក ហើយ បងប្អូនស្រែចំការយើងដែលជាអ្នកប្រកបដោយជីវភាពដុនដាបជាងគេបំ- ផុត ខំស្មុះស្មារធ្វើពលកម្មរែរម្មគ្នាស្រុះស្រួលអង្គាសប្រាក់គ្នាតាមតិចតាមច្រើន យកមកសង់សាលាទាំងខ្លួន ៗ ព្រមទាំងប្រដាប់ដោយគ្រឿងតុតាំងសព្វគ្រប់ ហើយផ្ដាច់ផ្ដាប់ផ្ទួនពងការសុំឲ្យតែបានកូនចៅរៀនសូត្របានបេះបានជំងឺនឹង ៗ

ទក ! យើងឃើញថា វិជ្ជាមានដម្លៃរកអ្វីផ្ទឹមគ្មាន ។ តែយើងត្រូវពិចារណាឲ្យមែនទែន ដើម្បីដុះមើលឲ្យឃើញថា ដម្លៃដែលយើងឲ្យទៅវិជ្ជានោះ តើនៅត្រង់ណា ?

បើយើងរកពិតឲ្យល្អិតទៅ យើងឃើញថា ដម្លៃនៃវិជ្ជាស្ថិតនៅច្រើនកន្លែង ។ តែបើឃើញនិយាយដោយសង្ខេបហើយឲ្យងាយយល់បានផង ដម្លៃនៃវិជ្ជា ឃើញថា អនុលោមទៅតាមការរៀបចំនៃសង្គមមនុស្ស ។ អ្នកដែលរៀបចំសង្គមឲ្យមានមនុស្សជិះជាន់សង្កត់កមនុស្ស ដើម្បីឲ្យអ្នកខ្លាំងពូកែជំរិតយកផលប្រយោជន៍ពីអ្នកទន់ខ្សោយជាងគេ គេត្រូវតែប្រើឲ្យបានសម្រេចបំណងលាមករបស់គេនោះ ហើយគេបង្ហាត់បង្រៀនតែវិជ្ជារបៀបនេះត ៗ ទៅទៀត ។ មានអ្នកមួយពួកទៀត គឺអ្នកដែលមានគំនិតរៀបចំសង្គមឲ្យបាត់មនុស្សកេងលើមនុស្ស ត្រឡប់ទៅជាឲ្យមនុស្សចេះពប់រកគ្នា ទទួលស្គាល់ដម្លៃគ្នាទៅវិញទៅមក ហុចប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ។ មនុស្សប្រសើរពួកនេះយល់ឃើញថា ដម្លៃនៃវិជ្ជា នៅត្រង់វិជ្ជាចេះធ្វើឲ្យមនុស្សលោះទុកខ្លួន គឺជួយយិតយោងស្រោចស្រង់មនុស្ស មិនមែនពន្លិចមនុស្សធ្វើឲ្យមនុស្សគាន់តែដុនដាបដុនខ្លួនទៅវិញទេ ។

បើយើងនិយាយខ្លីដូច្នេះ យើងឃើញថា វិជ្ជាមានពីរសណ្ឋាន ។

សណ្ឋានទី ១ គឺវិជ្ជាដែលធ្វើឲ្យមនុស្សចេះគុកនទន្ទ្រានគ្នាយកប្រយោជន៍ផ្ទាល់រៀងខ្លួន ៗ វិជ្ជាបែបនេះយើងសន្មតហៅថា ទុវិជ្ជា ព្រោះវិជ្ជានាំទុក្ខ នាំគឺអន្តរាយដល់មនុស្ស ៗ សណ្ឋានទី ២ គឺវិជ្ជាដែលធ្វើឲ្យមនុស្សចេះពប់រកគ្នាឲ្យមនុស្សចេះគិតប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ៗ វិជ្ជារបៀបនេះ យើងសន្មតឲ្យឈ្មោះថា សុវិជ្ជា ព្រោះជាវិជ្ជានាំសុខ នាំចំរើនឲ្យមនុស្ស ៗ

តទៅនេះ យើងនឹងលើកយកទុវិជ្ជាមកអធិប្បាយជាដំបូង ៗ

ទុវិជ្ជា —

យើងសូមរំឭកម្តងទៀតថា មុខវិជ្ជានៅក្នុងសង្គមជិះជាន់មនុស្សក៏ដូចជានៅក្នុងសង្គមកសាងមនុស្ស មិនខុសអ្វីពីគ្នាទេ គឺថាបើគិតតែសុទ្ធសាធវិជ្ជា វិជ្ជាសឹងមានដម្លៃតែមួយ គឺឲ្យមនុស្សយើងចេះដឹងឲ្យមានសកម្មភាពខុសអំពីសត្វតិរច្ឆានៗ តែអ្វីដែលនាំឲ្យយើងចែកវិជ្ជាជាទុវិជ្ជានឹងសុវិជ្ជា គឺការដែលមនុស្សបានវិជ្ជានោះមកហើយ យកទៅប្រើផ្លូវខុសឬក៏យកទៅប្រើផ្លូវត្រូវ ៗ

មនុស្សដែលប្រើវិជ្ជាទៅផ្លូវខុស គឺប្រើវិជ្ជាជាផ្លូវស្វែងប្រយោជន៍ផ្ទាល់ខ្លួនដណ្តើមប្រយោជន៍ពីអ្នកលទ្ធល់ខ្សោយនឹងខ្សត់ខ្សោយជាងខ្លួន ៗ ដូចយ៉ាងពួកបក្រពត្រអាណានិគមនិយមដែលគេជាអ្នកមានចំណេះវិជ្ជាសព្វសារពើពេញខ្លួន តែគេប្រើចំណេះគេប្រយោជន៍តែដើរជិះជាន់ប្រជាជនស្រុកទន់ខ្សោយប៉ុណ្ណោះឯង ៗ នៅ

ស្រុកគេៗ ប្រើវិជ្ជាជិះជាន់ប្រជាជនគេមួយជាន់ទៅហើយ ហើយគេចេញពីស្រុក មកជិះជាន់ប្រជាជនស្រុកអាណានិគម ដែលជាស្រុកបំណុះរបស់គេមួយជាន់ទៅទៀត ។

កាលបើគេមានគំនិតថា វិជ្ជាជាផ្លូវស្វែងលាភសក្ការៈរបស់គេដូច្នោះ គេក៏កើតមានគំនិតធ្វើបង់ឃាំងមិនឲ្យវិជ្ជាផ្សាយទូទៅដល់ប្រជាជនភាគច្រើនឡើយ គេទុកឲ្យតែមនុស្សភាគតិច គឺពួកគេនោះឯងរៀនបានហើយ ព្រោះគេខ្លាចមនុស្សរៀនច្រើនគ្នាមកប្រជែងដណ្ដើមយកផលប្រយោជន៍ពីគេ ។ គេក៏តាំងធ្វើឲ្យជឿថា អ្នកដែលស្វែងវិជ្ជាបានទាល់តែមានទិស្ស័យ គឺទាល់តែទេវតាដៅទុកមកហើយ បើតាមខ្មែរយើងគឺថា ទាល់តែបានកសាងអំពីជាតិមុន គឺបានតែមនុស្សភាគតិចនោះឯង ។ គេបំភាន់គំនិតអ្នកភាគច្រើនបានដូច្នេះហើយ គេតាំងប្រើល្បិចបង្កើតឧបសគ្គគ្រប់បែបគ្រប់យ៉ាងដើម្បីធ្វើឲ្យការស្វែងវិជ្ជានោះពិបាកមែនចំ-ពោះជនភាគច្រើន ដូចជាការប្រឡងប្រជែងដណ្ដើមយកវិជ្ជាជាដើម ។

ឧត្ដមគតិពួកចក្រពត្តិអាណានិគមនិយមគឺដូច្នេះឯង ។ ម្ល៉ោះហើយដើម្បីបំភាន់ឲ្យប្រជាជនគេ នៅស្រុកគេជឿគេធ្វើឲ្យប្រជាជនគេនោះភាន់គំនិតថាដែលគេយកប្រទេសទន់ខ្សោយជាអាណានិគម គឺប្រយោជន៍ផ្សាយវិជ្ជាប្រសើររបស់ជាតិគេ ហើយគេបំភាន់ទៀតថា ជាតិគេជាអ្នកមានវិជ្ជាត្រូវតែធ្វើជាចៅ

ហ្វាយនាយលើជាតិល្ងង់ខ្លៅ តែដោយពិតទៅគេដើរលើក្បាលទាំងប្រជាជនជាតិរបស់គេ ទាំងប្រជាជនស្រុកអាណានិគម ។ គឺប្រជាជនដែលឲ្យពួកគាត់គាបនេះបន្ទុំបាន ត្រូវទទួលរងវេទនាបំពេញប្រយោជន៍ពួកនេះទាំងអស់គ្នាដោយមិនដឹងខ្លួន ។ គ្រប់ប្រទេសដែលមានស្រុកចំណុះ គេបង្កើតសាលាមួយ ឲ្យឈ្មោះថា «សាលាអាណានិគម» ។ ចំពោះប្រជាជនស្រុកគេ គោលបំណងសាលានេះគឺសំរាប់ផ្សាយវិជ្ជាដល់ស្រុកចំណុះ តែការពិតទៅសាលានេះសំរាប់តែបង្ហាត់បង្រៀនពួកជើងដៃគេឲ្យមកបន្តការជិះជាន់របស់គេនៅស្រុកអាណានិគម ។ នៅឯស្រុកអាណានិគមវិញ ក្នុងការសិក្សាគេយកភាសារបស់គេជាធំ ឯភាសារបស់ស្រុកនោះវិញគេទុកជាគ្មានបានការ ដ្បិតតែពួកអាណានិគមនិយមគេមិនគិតដល់ប្រជាជនស្រុកណាដែលគេកាន់កាប់នោះទេ ។ គេទុកប្រជាជនស្រុកអាណានិគមជាកម្លាំងមួយដ៏សំខាន់សំរាប់បង្កើនប្រយោជន៍ឲ្យគេ ។

ដើម្បីនឹងធ្វើយ៉ាងនេះបាន គេរកមធ្យោបាយគ្រប់យ៉ាង កុំឲ្យអ្នកស្រុកនោះចេះជ្រៅជ្រះ ។ ភាសារបស់គេជាផ្លូវមួយ ដើម្បីពកពង់កុំឲ្យកូនប្រទេសអាណានិគមលូតលាស់បាន ។ មានរបៀបច្រើនទៀត ដូចជាកម្មវិធី ។ កម្មវិធីជាកម្មវិធីសំរាប់នៅប្រទេស គឺវាគ្មានទំនោរតាមផលប្រយោជន៍ ប្រទេសអាណានិគមទេ ដូច្នោះឃើញថា ក្នុងការរៀន ឬគ្រូមិនសូវរៀនឲ្យតែចាំមាត់ដូចសេក គ្មានបានគិត

គួររកហេតុផលអ្វីវែងឆ្ងាយទេ គឺគេមិនត្រូវការអ្នកចេះគិត គេត្រូវការតែអ្នកធ្វើតាមបង្គាប់គេតែប៉ុណ្ណោះ ៗ ឯសៀវភៅសម្រាប់បង្រៀនវិញ គេយកតែសៀវភៅស្រុកគេមកឲ្យរៀន ដូច្នោះក្នុងការរៀនសូត្រ ឃើញតែឲ្យស្រឡាញ់ស្រុកគេ ឲ្យតែស្គាល់ស្រុកគេ ឯស្រុកឯងវិញដែលរស់នៅរាល់ថ្ងៃទៅជាមិនដឹងអ្វីឲ្យប្រាកដ ៗ

ឯរបៀបរៀនគឺរៀនដោយបន្ទំ កំហែងគំរាម ៗ ដល់រៀនទៅពុំសូវបានផល គេថាប្រជាជនស្រុកនោះល្ងង់ណាស់ ស្ពិកណាស់សំតែគេត្រួតទើបរស់បាន ៗ ឯលោកគ្រូគេដែលជាអ្នកបង្រៀនក៏លាក់លាបបំណោះទៅទៀត គេបង្រៀនសំពប់តែល្មមធ្វើការឲ្យគេបានទីដ៏ចេះចាំទទួលបង្គាប់គេប៉ុណ្ណោះ ៗ សរុបទៅក្នុងការរៀនសូត្រ ប្រជាជនប្រទេសអាណានិគមគ្មានបានជំរេះប្រាជ្ញាទេ ពីព្រោះរៀនដូចយល់សប្ត ៗ លុះដល់ទៅធ្វើការរកស៊ី ដោយខ្លួនពុំដែលរៀនគិត ប្រជាជនអស់នោះលែងទុកចិត្តខ្លួនឯង ចាំតែគេធ្វើឲ្យ បំណែកខាងខ្លួនឯងវិញ សូមតែរស់ក្នុងមួយជីវិតនេះ ទំពាំទឹងស្លាប់ ៗ បែរខាងការពុករលួយវិញ គេខំផ្សាយតែពាសពេញ ដូចជាប្រណោមលោកខាងស្រើបស្រាល ខ្សែភាពយន្តពុករលួយ ៗ

ដើម្បីនឹងឲ្យគេបាននៅស្ងិតស្ងេរទៅទៀត គេត្រូវការពួកអ្នកការពារគេ អ្នកអស់នេះគេមិនបាច់ទៅរកឆ្ងាយទេ គេយកតែប្រជាជននៅស្រុកអាណានិគម

នោះ ដោយគេប្រកាសថាស្រុកនិមួយៗត្រូវមានអ្នកការពារ ៗ ការរើសទាហានរើសគិញនេះជាការត្រូវណាស់ ស្រុកនិមួយៗត្រូវការការពារខាងក្នុងប្រទេសក៏ដូចខាងក្រៅប្រទេស ៗ តែទាហានគិញនៅប្រទេសអាណានិគមនិមួយៗឃើញតែបំរើផលប្រយោជន៍អ្នកអាណានិគមនិយមទៅវិញ ឃើញតែធ្វើបាបប្រជាជនជាតិដូចគ្នា សម្លាប់តែគ្នាឯង ព្រោះគេបានបង្ហាត់ទាហាន គិញអស់នោះឲ្យចេះតែសម្លាប់តែគេមួយ ក្រៅពីនោះគេឲ្យគិតតែពីការសប្បាយ អំពើពាលាគ្រប់បែបគ្រប់យ៉ាង ៗ ដូច្នោះគេច្រើនឃើញទាហានគិញជនជាតិប្រទេសអាណានិគមធ្វើបាបតែជនជាតិឯង ដើម្បីប្រយោជន៍ចៅហ្វាយចក្រពត្រជិះជាន់ ៗ

ខាងសិល្បៈគេបណ្តុះបណ្តាល ការស្រើបស្រាលធ្វើឲ្យវិលខួរលក្បាលស្រវឹងសប្បាយ ប្រយោជន៍គេឆាយទិញយកទៅបំរើប្រយោជន៍ឲ្យគេ ៗ

វិទ្យាសាស្ត្រគេឲ្យយើងចេះទ្រឹស្តីព្រាលៗយកមកអនុវត្តន៍ក៏មិនបានជាអ្វីព្រោះគេទុកផ្លូវយកផលអនុវត្តន៍ទៅស្រុកគេមកលក់ឲ្យយើង យកបំណេញការកម្ម យកមកកំហែងយើងកាលណាយើងមិនព្រមចុះញ៉មគេ ឬយកមកលួចឆក់យកការពីយើង ៗ

ឯខាងនយោបាយវិញ គេបង្ហាត់ឲ្យធ្វើនយោបាយក្តៅក្រហាយ ដើរបំបែកបំបាក់ ចាក់អ្នកនេះញុះញង់អ្នកនោះ គឺនយោបាយជិះជាន់ប្រជាជនទៅក្នុងស្រុក

នឹងនយោបាយសង្គ្រាមនៅក្រៅប្រទេស ។

វិជ្ជាទាំងអម្បាលម៉ាណាដែលប្រើខុសផ្លូវដូច្នេះហៅថាទុវិជ្ជា ។ ដោយយើងឃើញថាទុវិជ្ជា នាំបំផ្លាញយើង បំបែកបំបាក់យើងធ្វើឲ្យយើងលែងទុកចិត្តគ្នា គួរតែយើងខំតម្រង់វិជ្ជានេះឲ្យទៅជាសុវិជ្ជាទៅវិញ ។ ក្នុងទស្សនាវដ្ដីយើងលេខក្រោយយើងនឹងអធិប្បាយពីសុវិជ្ជា ។

—ooo—

# បញ្ហាអនាម័យ

## សុខភាព

ពាក្យនេះមានន័យថា « ភាពជាសុខ » ឬ « សេចក្ដីសុខ » បើពាក្យធម្មតា ប្រែថាគ្មានជម្ងឺ ។ យ៉ាងដូច្នេះប្រទេសណាដែលប្រជាជនមានសុខភាពល្អ ជាប្រទេសមានលាភមួយដ៏ប្រសើរ ព្រោះបុគ្គលគ្មានជម្ងឺជាកម្លាំងរបស់រដ្ឋ តាមផ្លូវកាយក៏ដូចតាមផ្លូវវាចានិងផ្លូវចិត្តដែរ ជម្ងឺជាគ្រឿងបណ្ដាលឲ្យបុគ្គលគ្មានសតិអារម្មណ៍ទឹងទួន ឲ្យប្រជាជនទាំងភូមិរត់បោលផ្ទះសម្បែង (មានជម្ងឺអាសន្នរោគ, បេស្ដិ អុតធំជាដើម ) ឲ្យផលប្រយោជន៍នៃសេដ្ឋកិច្ចរបស់ស្រុកឲនថយ (ជម្ងឺគ្រុនចាញ់) ដំឡើងនូវចំណាយសំរាប់ទិញថ្នាំ ពង្រីកផ្ទះពេទ្យ (ដើម្បីជាកិច្ចផ្ដល់តាមតំរិតចំនួនអ្នកជម្ងឺ ). . . ពិសេសជម្ងឺជាបីសាចបំបែកគំនិតប្រជាជាតិឲ្យបែកបាក់គ្នា ។ ឃើញកម្លាំងរបស់ជម្ងឺគួរឲ្យខ្លាច គួរឲ្យព្រឺ ៗ បុគ្គលម្នាក់ ៗ ត្រូវតែតស៊ូដើម្បីការពារសុខភាពផ្ទាល់ខ្លួន កុំឲ្យរបេះខ្លាយជា « ទុក្ខភាព » វិញ ព្រោះ « ទុក្ខភាព » ជាឧបសគ្គលើបុគ្គល លើគ្រួសារ ពិសេសគឺលើជាតិដែល

ជាទីគោរពនឹងស្នេហានៃយើងពល់គ្នា ។

ទី១ – ខ្ញុំយកបញ្ហាសុខភាពដែលកើតមកអំពីផ្ទះសម្បែង ដ៏គួរមកអធិប្បាយជូនជាបឋម ។ ប្រជាជនខ្មែរគ្រប់ប្រភេទ តែងតែជួបនឹងការលំបាកក្នុងការសង់ផ្ទះមួយគ្រឿង (ដែកសុំម៉ងត៍ ថ្នាំលាបផ្ទះ គ្រឿង «ពកសឺឡែន» ជាដើម) ព្រោះសុទ្ធតែជាគ្រឿងចេញដោយស្នាដៃបរទេសទាំងអស់ ។ នេះជាហេតុមួយបណ្តាលឲ្យតម្លៃផ្ទះនីមួយៗថ្លៃហួសកំរិត ។ មិនតែប៉ុណ្ណោះឈ្នួលសង់ផ្ទះទៀតក៏ថ្លៃដែរ លើសពីនេះទៅទៀត គ្រឿងខ្លះដូចជាឈើ ក៏មានតម្លៃអថម្មជាតិ (ថ្លៃទាំងឈ្នួលអា, ថ្លៃទាំងឈ្នួលដឹកនាំ) ។ ហេតុនេះការសង់ផ្ទះជាការលំបាកណាស់ ចំពោះគ្រួសារដែលមានជនជានមធ្យម ។

អំពីរឿងផ្ទះនេះ ខ្ញុំសូមនិយាយអំពីខ្នាតគតិរបស់ប្រទេសដែលប្រកបដោយអារ្យធម៌មែនៗ ។ គ្រួសារខ្លះមានបំណងចង់បានគេហស្ថានទៅជាប់តែឯង ខ្លះចង់នៅជាពួកដោយមានសួនច្បារក្តី គ្មានក្តី ដែលជាមូលហេតុនៃចំនួនកូនដែលមាននៅក្នុងគ្រួសារនោះ ឬតាមបំណងរបស់បុគ្គលម្នាក់ៗ ឬតាមកម្លាំងរបស់សង្គមជាតិ ។ ពាក្យបចាមអាពមក៏មានពោលថា: ផ្ទះងងិតទាត់ជាផ្ទះប្រកបដោយគ្រោះថ្នាក់, ពីព្រោះផ្ទះ ៖

ក – គ្មានពន្លឺព្រះអាទិត្យចូល ជាហេតុឲ្យមេរោគរស់នៅបានដោយងាយ

ខ - ខ្វះខ្យល់ « ឧស៊ីហ្សែន » ដកដង្ហើម

គ - មានផ្សែង « កាបូនិក » ដែលជាគ្រឿងពុលអប់នៅហួសកំរិត

ឃ - មានមេរោគអាចជ្រកពួនចាំចម្លងដម្ងំបានដោយងាយ ៗ

មិនតែប៉ុណ្ណោះ ការបង្អៀតបង្អល់ចប់ចិត្ត-គំនិតអាចកើតមានឡើងដោយ :

ក - កំដៅកំដៅហួសកំរិត

ខ - ខ្វះកន្លែងសំរាប់ឲ្យខ្យល់អាកាសផ្លាស់ប្តូរ

គ - ក្លិនសំអុយបន្ទុយនូវការរស់ជាតិរបស់អាហារ

ឃ) ខ្វះរនុះពន្លឺខ្វះ ៗ

ការបង្អៀតបង្អល់នេះ នឹងបណ្តាលឲ្យមានសភាពខ្ពង់ទៅទៀត កាលបើផ្ទះសង់នៅជាប់គ្នា ៗ ហេតុនេះហើយបានជាមនុស្សលោកចូលចិត្តបើកបង្អួចនៅលេងកណ្តាលវាល ទីស្រែចំការ ដែលមានខ្យល់អាកាសត្រជាក់ ស្អុត អាចផ្លាស់ប្តូរបានដោយងាយ ព្រោះខ្យល់អាកាសនៅស្រែឬក្នុងជាថ្នាំសំរាប់លើកកម្លាំងសរសៃវិញ្ញាណនិងសរសៃឈាមរបស់យើង ដែលជាហេតុធ្វើឲ្យយើងទូលាយចិត្តប្តូគំនិត ៗ

មានយោបល់មួយថា « ការថែរ - សមរម្យជាគ្រឿងចាំបាច់របស់សុខភាព »។

យ៉ាងដូច្នេះ គ្រួសារនិមួយ ៗ ត្រូវការរស់នៅក្នុងផ្ទះ ដែលធំទូលាយជាគ្រឿងធ្វើ

ឲ្យគ្មានទឹងចិត្តបានជួបនឹងការជូរចត់ឈ្លាយដែរ ។ ពន្លឺព្រះអាទិត្យ កំដៅព្រះអាទិត្យ ទឹក- ទំហំខ្យល់អាកាសជាគ្រឿងចាំបាច់សំរាប់អប់រំមេ្យកាយនឹងចិត្ត ។ បុគ្គលម្នាក់ៗត្រូវការសម្រាកខ្លួនប្រាណ កាលដែលវិលត្រឡប់មកពីប្រកបការងារវិញ ចុះត្រឡប់មកផ្ទះឃើញផ្ទះងងឹតក្រខ្វក់ ព្រួសរអ៊ូអរ ធុំក្លិនស្អុយ គ្រឿងវិញ្ញាណខន្ធនឹងរកពេលសម្រាកបានដែរឬទេ ? ភ្នែកត្រូវការមើលវត្ថុដែលគាប់គួរមានពន្លឺជាដើម ប្រមុះត្រូវដៀសវាងក្លិនគំរុង គ្រចៀកត្រូវការស្ងប់ស្ងាត់បន្តិច ៗ បើដូច្នេះគ្រួសារដែលនៅក្នុងសង្កាត់ ភូមិ ឃុំក្រខ្វក់ សង់ផ្ទះបង្អៀតជាប់គ្នាមិនទៅជាកន្លែងនៃការគាំងគិនបរិត ស្រពោនចិត្តទៅហើយ កូនតូចៗដែលត្រូវការកន្លែងសម្រាប់រត់លេង ដកស្រូបយកខ្យល់អាកាសស្អាតឬក៏គ្មាន បែរគ្រប់ទិសឃើញតែជញ្ជាំងផ្ទះក្រឡេកមើលទៅលើឃើញតែផ្សែងពូនជាដុំ នឹងឮលឺហួយស្រពោង គ្រចៀកទទួលតែសព្ទសម្លេងខ្លួ យ៉ាងដូច្នេះនឹងរកសុខភាពឯណាបាន ? ចំពោះរឿងផ្ទះសំបែងនេះតើយើងត្រូវចាត់វិធានការណ៍បែបណាដើម្បីនឹង:

១)-ឲ្យថ្លៃសង់ផ្ទះបានថោក ។

២)-បំបាត់ផ្ទះស្លឹកចោល ។

យោបល់របស់ខ្ញុំគួរឲ្យមានសមាគមថ្មី សំរាប់សង់ផ្ទះ ដែលមានការទទួលសង់ផ្ទះរាជការនឹងផ្ទះឯកជន ៗ សមាគមនេះមានសារៈប្រយោជន៍ដូចតទៅ:

ក – អ្នកដែលត្រូវការសង់ផ្ទះមិនខាតពេលនឹងគិតទិញគ្រឿងឈើសំកុកខាតពេលជាច្រើនខែ ដើម្បីត្រួតត្រាមើលជាងសង់ផ្ទះ ពិសេសទៅទៀត មិនកើតការព្រួយនឹងដើរខ្ចីបុលលក់បញ្ចាំរបស់ដើម្បីទិញគ្រឿងនឹងថ្លៃឈ្នួលជាងៗ ចំណុចត្រង់នេះខ្ញុំសូមបញ្ជាក់ថា សមាគមសង់ផ្ទះនេះអាចបន្ធូរថ្លៃផ្ទះ ពីអ្នកពលករដែលត្រូវកាត់ប្រាក់ខែ សងថ្លៃផ្ទះរបស់ខ្លួន ទៅសមាគមវិញ តាមភាគរយនៃប្រាក់ខែរបស់ខ្លួន ដើម្បីទុកប្រាក់ខែខ្លះ សំរាប់ចិញ្ចឹមគ្រប់គ្រងគ្រួសារ ព្រោះខ្ញុំបានពិតមានថាអ្នកពលករ ច្រើនតែក្រខ្លួន ចំពោះសង់ផ្ទះបានមួយៗ ត្រូវតែការប្រាក់ខ្ចីគេប្រាក់ដោះប្រាក់ដើមទៀត ” ។

ខ) សមាគមនេះ ជាសាលាបង្រៀនសំរាប់បណ្តុះបណ្តាលយុវជនខ្មែរ នូវវិធីសង់ផ្ទះនឹងជាកន្លែងសម្រាប់រំលែកបន្ទុកខ្លះពីពលករ ព្រោះអ្នកដែលចូលរៀននោះបានទាំងចំណេះបានទាំងប្រាក់ខែឬប្រាក់រង្វាន់ទៀតផង ។

បន្ទាប់មក ខ្ញុំពណ៌នាអំពីការទាក់ទងរវាងព្រះអាទិត្យ ពន្លឺ-ខ្យល់ ធូលីនឹងផ្សែង ជាមួយនឹងសុខភាព ។

១ – ព្រះអាទិត្យនឹងពន្លឺ

ផ្ទះនិមួយៗ នឹងមានសុខភាពបាន លុះត្រាតែកាំរស្មីព្រះអាទិត្យបាញ់ចូលទៅសព្វបន្ទប់ ។ កាំរស្មីនៃព្រះអាទិត្យ ស្រូបយកអាកាសដែលជ្រាបសើម

នៅក្នុងផ្ទះ ថែទាំបរិញ្ញាណនឹងគ្រឿងកាយរបស់មនុស្ស សម្លាប់មេរោគហើយ បំផ្លាញនូវគ្រឿងស្អុយ ៗ ចំពោះខ្លួនឯងវិញ កាលបើកាំរន្ទះពណ៌ខៀវខ្លាំង «រ៉ៃយ៉ុងអ៊ុលត្រាវីយ៉ូឡេ» បានប៉ះទៅលើស្បែកវា អាចគាំពារខ្លួនឯងនោះ នឹងជម្ងឺ ហើយផ្តល់កម្លាំងដើម្បីការពារនឹងជម្ងឺផ្សេង ៗ ទៀត ។

ពន្លឺព្រះអាទិត្យផ្តល់ក, ជាទីគាប់ចិត្តរបស់មនុស្ស ។ ការដែលបន្ទា ទោសមនុស្ស ដោយយកទៅដាក់ក្នុងបន្ទប់ងងឹតជាអំពើវាកិច្ចមួយ អាចធ្វើឲ្យចិត្តរបស់អ្នកនោះឯងអន់ថយនូវស្មារតី សតិបញ្ញា ៗ មិនតែប៉ុណ្ណោះ មានខ្លះ ដែលស្មារតីចុះខ្សោយស្រាប់ សភាពងងឹតនេះវាអាចបណ្តាលឲ្យឆ្កួតបាន ។ យ៉ាងដូច្នេះទណ្ឌកម្មដោយយកមនុស្សទៅដាក់ក្នុងបន្ទប់ងងឹតនោះជាទណ្ឌកម្មយ៉ាង កំណាចដែលជាគ្រឿងសំពប់គ្របសង្កត់លើចិត្តរបស់មនុស្ស ។ ពន្លឺស្រង ៗ ស្រអាប់នាំឲ្យអស់កម្លាំងឆាប់ខូចភ្នែក ។ នៅក្នុងបញ្ហានេះ យើងត្រូវងាក សម្លឹងទៅសាលារៀន ដែលក្នុងថ្នាក់នីមួយ ៗ សិស្សានុសិស្ស ត្រូវការឲ្យមាន កាំរស្មីព្រះអាទិត្យនិងពន្លឺ ដើម្បីនឹងប្រកបការរៀនសូត្រស្របទៅតាមការចំរើន ជីពិតក្រុមគជ ។

២= ខ្យល់:

ខ្យល់អាកាសស្អាតត្រជាក់ ក៏ល្អជាកម្លាំងសម្រាប់ជួយដំណើរនៃសរសៃ

វិញ្ញាណ ៗ អ្នកខ្លះបានឲ្យការថា «គួរតែដកបើកបង្អួច ដើម្បីឲ្យមានការផ្លាស់ប្តូរនូវខ្យល់អាកាស» ៗ ចំពោះខ្យល់អាកាសនេះ បើសិនណាជាយើងឆាកទៅមើលរោងល្ខោន ពិសេសបំផុតគឺរោងកុន ដែលជាកន្លែងហាប់ប្រកបដោយមនុស្សចំនួនច្រើន ជក់ក្លិនញើស ក្តៅស្អុះស្អាប់ (ពិតមែនហើយតែទៅក្នុងរោងកុនមានដង្ហាល់វិសាលច្រើន តែខ្យល់នោះវាវិលវល់ផ្តុំគ្នាតែមួយកន្លែង) យើងឃើញថាខ្យល់គ្មានផ្លាស់ប្តូរទាល់តែសោះ ៗ អ្នកដែលទៅមើលកុនដកស្រូបយកខ្យល់ក្រខ្វក់ដែលចេញពីសួតអ្នកដែលមានជម្ងឺ ផ្សែងបារីក្អកប្រចុះ ហេតុនេះហើយបានជាអ្នកមានអត្តពលទន់ខ្សោយច្រើន តែងឈឺ ក្រោយដែលពេលចេញមកពីមើលល្ខោន កុន វិញ ៗ ក្នុងរឿងនេះ ខ្ញុំសូមលាតត្រដាងចំពោះអាបក្សារិយានៃគ្រួសារខ្លះ ដែលពរកណ្តៀតបីដឹកដៃនាំកូនតូចធំចូលទៅក្នុងរោងកុនឲ្យយំរញ៉ាំករញ៉ូច ព្រោះក្មេងវាភ័យកាលបើងងឹត ទាំងផ្សែងក្អកបប់ដង្ហើម ដោយផ្សែងបារី ខ្យល់ដង្ហាល់ទាំងខ្យល់ក្រខ្វក់អាប់អួរនៅក្នុងរោងកុន ៗ ទារកខ្លះដោយសារស្នាដៃឪពុកម្តាយដែលពរបី កណ្តៀត យកទៅមើលកុននោះ សឹងត្រូវទទួលឈឺជម្ងឺខ្លះក៏ធ្ងន់ធ្វើឲ្យគ្រួសារមិនគ្រាន់តែខូចប្រាក់ពាន់ គឺឡែបក្អែកម្តង ៗ បាន ៗ ខ្ញុំសូមបន្ថែមថាការរស់នៅ ៗ ក្នុងទីកន្លែងដែលមានខ្យល់អាកាសក្រខ្វក់ហាប់អាប់បណ្តាលឲ្យមានគ្រោះថ្នាក់ដូចតទៅ :

ក– ចំពោះគ្រឿងសរសៃវិញ្ញាណ : ឆាប់ហត់, ឈឺក្បាល-ខ្យល់គរ មានដល់ទៅស្លាប់ ។

ខ– ចំពោះគ្រឿងសរសៃឈាម: ចឹបចរ កម្លាំងឈាមក្នុងសរសៃ នឹងបេះដូងខ្សោយដំណើរមិនស្មើទៅកំរិតកំដៅក្នុងខ្លួន ។ ចំពោះរឿងនេះបានជា នៅស្រុកក្តៅគេមិនឲ្យមនុស្សឈរជិត ៗ គ្នាពេក ដើម្បីកុំឲ្យចំហាយកំដៅដែល ចេញពីខ្លួនផងប៉ះទៅលើគ្នា ហើយត្រូវពាក់តែខោអាវក្រណាត់ស្រាវៗដែរ ដើម្បីឲ្យខ្យល់ ក្តៅនឹងសើមអាចចេញពីសំពត់អាវបានងាយ ។

គ) ធ្វើឲ្យស្រេកទឹក ប្រែជាស្រេកស្រាតាំមាន ។

៣ ) ធូលី:

ធូលីកើតមកអំពីដីខ្សាច់-ឈើ-ធ្យូង កំទេចលាមកគ្រាមគ្រប់ភេទ ។ គេ ក្រឡេកមើលតាមបង្អួចយើងអាចឃើញអ្នកផ្ទះជះផ្ទុះសំពត់អាវ វាយពូក មើលទៅក្នុង ផ្ទះ តាមផ្លូវថ្នល់ ក៏ឃើញគេបោសសម្អាត (ដោយមិនប្រើទឹកលាងបង្កត) បណ្តាល ឲ្យធូលីហើរចូលក្នុងច្រមុះ ។

៤) ផ្សែង:

«ផ្សែងជាធូលីលាយជាមួយនឹងប្រេងភ្លើង» ។ នៅក្នុងទីក្រុងដែលមាន រោងចក្រដុះពាសពេញ គេសង្កេតឃើញបង្អួចប៉ះសើមតែគ្រប់ផ្ទះ ។ ប្រជាជន

ដែលនៅទីកន្លែងនេះត្រូវខ្សោយស្ងួត ដោយត្រូវដកដង្ហើមបញ្ចូលតែអាកាសក្រខ្វក់ជាទីបំផុត ។ មិនតែប៉ុណ្ណោះ ផ្សែងអាចធ្វើឲ្យការទ្រុះថ្ងៃទទួលថយនូវកម្លាំង ដែលជាហេតុបណ្ដាលឲ្យកូនក្មេងមានកើតជម្ងឺ (គឺជម្ងឺមិនរឹងប៉ឹង) ។

ទី២ – អាហារជាគ្រឿងចាំបាច់សម្រាប់គាំពារសុខភាព ។ ខ្វះអាហារ ឬអាហារមិនគ្រប់គ្រាន់ដោយចំនួនឬដោយជាតិ ធ្វើយថាអន់កម្លាំងកាយ សតិអារម្មណ៍ក៏ខ្សោយតាមហ្នឹងដែរ ។

ទី៣) – ការរៀបចំទីក្រុងជាបញ្ហាពិសេសចំពោះសុខភាពរបស់ប្រជាជន ។ ប្រជាជននៅក្នុងក្រុងនោះទឹងជាកញ្ចក់ឆ្លុះអារ្យធម៌នៃជាតិនោះឯង ។ ក្រុងក្រខ្វក់ស្អាតអាក្រក់ល្អ ប្រស្រ័យទឹងអគ្គការៈ ។

ក) អគ្គការពជការដែលបេះរៀបចំក្រុងតាមរបៀបសម័យ

ខ) សតិអារម្មណ៍របស់រាស្ត្រ ដែលត្រូវបេះគោរពច្បាប់មិនចំពោះជាតិណាប៉ានៈណា ។

ធម្មតាពជការ ច្រើនតែជួបប្រទះនឹងការខ្វះប្រាក់ នឹងការអន់ខ្សោយខាងផ្នែកតិកនិក ។ ចំពោះស្រុកដែលមានអារ្យធម៌ទន់ខ្សោយ គឺស្រុកចំណុះគេ ឬទើបតែនឹងរួចខ្លួនជាអ្នកជានោះ ការរៀបចំក្រុង ជាការលំបាកជាទីបំផុត ព្រោះពជការដោយខ្វះការពិសោធន៍អាចធ្វើការដោយក័ក្ដប្រឹង្សាក៏មាន ។ បើមានការក័ត្តប្រ-

ទុំក្នុងការរៀបចំក្រុងហើយ ត្រូវចំណាយពេលម៉ោងយ៉ាងតិចត្រឹម ៥០-៧០ ឆ្នាំ ដើម្បីធ្វើឲ្យក្រុងនោះមានសភាពតាមយុគសម័យបាន ព្រោះត្រូវដោះស្រាយបញ្ហាទឹក បញ្ហាផ្លូវ បញ្ហាភ្លើង បញ្ហាល្អ បញ្ហាបង្ហាប់សំរាប់ក្រុង ។ល។

ទីបញ្ចប់ខ្ញុំយកបញ្ហាសុខភាពនៃគ្រួសារមកពណ៌នាដូចតទៅះ ប្រទេសណាដែលប្រជាជនមានសុខភាពបរិសុទ្ធល្អជាប្រទេសប្រកបដោយអារ្យធម៌ និងសម្បូរសប្បាយគ្រប់ចំពូក ៗ គ្រួសារដែលគ្មានជម្ងឺ តែងតែរស់នៅក្នុងបរិយាកាសល្អ ព្រោះមេគ្រួសារ បានទទួលនៅសេចក្ដីស្ងប់ស្ងាត់ គ្មានការចំណាយដោយការទិញថ្នាំ ឈ្នួលពេទ្យ ទឹកមុខក៏ប្រកបដោយសេចក្ដីរីករាយទៀត ។ ចំណែកឯគ្រួសារដែលមានជម្ងឺវិញ ការសុខសាន្តឆ្ងាយជាគ្មាន ព្រោះបើមានឈឺមិនមែនតែម្នាក់ទេ វាច្រើនតែច្រើនគ្នា ឬមួយជាមួយឈឺ បណ្ដាក់គ្នាដូចជាខ្វង់ ម្ល៉ោះហើយការមួរម៉ៅក្ដៅក្រហាយ វាមកគ្របសង្កត់មិនឲ្យការរីករាយសុខសាន្ត មានជីវិតបាន ។ បើមេគ្រួសារជាអ្នករកការឈឺរវល់តែទៅពេទ្យ បើទៅពេទ្យច្រើនដង ចៅហ្វាយនាយក៏មិនសូវសប្បាយចិត្តដែរ ព្រោះធ្វើការមិនបានផល ។ ម្ល៉ោះហើយកាលបើត្រឡប់មកផ្ទះវិញច្រើនតែផ្ញើសេចក្ដីតូចចិត្តខឹងបញ្ចូលមកក្នុងគ្រួសារដោយខុសចិត្តចៅហ្វាយនាយ និងអាក់ខានទីវាសនារបស់ខ្លួន ។ យ៉ាងដូច្នេះសមាជិកនៃគ្រួសារទាំងមូល រស់នៅក្នុងសេចក្ដីស្រ

ពន់ស្រពោនអាប់អួរក្នុងចិត្តជានិច្ច ៗ បើប៉ះលើជម្ងឺធម្មតាគ្មានវេទនានោះ ការតានតឹងចិត្តមានគំនិតមធ្យមល្មម បើជាយកប្រាក់ទៅទិញជម្ងឺស្រានឹងកាមរោគជាដើមវិញអ្នកជម្ងឺខ្លះមានទទួលបន្ទោសប្រពន្ធ បែរជាកើតហេតុទាស់ទែងខ្វែងគំនិតគ្នា ៗ យ៉ាងដូច្នេះសុខភាពបរិសុទ្ធល្អ ជាលាភពិសេសដែលបុគ្គលម្នាក់ ៗ គួរតែក្រេប ដែលគ្រួសារត្រូវតែថែទាំគាំពារ ដែលប្រជាជាតិត្រូវតែតស៊ូកុំឲ្យរបេះចេញបាន ព្រោះសុខភាពនេះវាជាកម្លាំងលើបញ្ហាផ្សេង ៗ របស់ស្រុក ៗ

ហេតុនេះ អ្នកស្នេហាជាតិគ្រប់ប្រភេទ មុខតែរិះរកមធ្យោបាយ សំរាប់សុខភាពបរិសុទ្ធ របស់ប្រជាជាតិជាមិនខាន ៗ

—o ▢ o—

# រឿងកំសាន្ត

## ចៅមាណពនឹងព្រាបស

អាគ្រាត្រស្ងាត់ អាកាសត្រជាក់ ទឹកសន្សើមធ្លាក់ជោគស្មៅ ៗ ផ្កាម្លិះ កូឡាប បំប៉ី យីថូ ដែលកំពុងរីកភាយពោលខ្លួនគ្រអូបឈ្ងប់ពេញសួនច្បារ ។ ពន្លឺព្រះចន្ទដែលជិតលាចាករាត្រីស្ងាត់ទៅហើយនោះ បានបំភ្លឺឲ្យឃើញចៅមាណពម្នាក់ ដើរទ្រេតទ្រោតចូលមកក្នុងសួន ប្រាស់ខ្លួនដេកក្បែរគល់កូឡាបមួយ ៗ

មាន់រងាវ-ក្អែកខ្វែក• តាវៅយ៉ុំ. សត្វឃ្មុំចេញត្រេបលំអងផ្កា, អ្នកស្រែបំការស្រែកគោកហៅគ្នីគ្នាម្នីម្នាទៅធ្វើការរៀងខ្លួន ព្រះអាទិត្យរះពេញពន្លឺ តែចៅមាណពកំពុងលក់ដូចសក្ដភាម ហាក់ដូចជារវើយខ្លាំងណាស់កាលពីល្ងាច ៗ

មួយស្របក់មានព្រាបសឈ្មោលញីមួយគូរហើរបន្ទាបមកចុះក្នុងសួន បណ្ដើរគារកចំណីយ៉ាងរីករាយ ៗ ឃើញចៅមាណពដេកមិនទាន់ក្រោក ព្រាបសទាំងគូរនឹកសង្ស័យជាខ្លាំង ក៏ដើរមកជិតហើយសួរយ៉ាងសុភាពថា « មាណពចៅអើយ អរុណរះពេញពន្លឺហើយ ម្ដេចក៏ចៅនៅមិនទាន់ក្រោកទៀត ? ចៅ

ឮសូរញញូរដានដែកកំពុងដំទេ? ចៅក្រោកឡើងមើលអ្នកស្រែទាំងហ្វូងៗកំពុងខំប្រឹងប្រូតស្រូវ ។ ចៅឮមាត់ក្មេងកំពុងរៀនទេ? ហ្ន៎! ចៅមើលអ្នកលក់ដូរកំពុងខំមមីមមាទៅផ្សារ ។ នៃចៅមាណព ចៅមើលនោះ សត្វត្មាតវាកំពុងបុះដុំវិញសួនច្បាររបស់ចៅហើយ ចៅក្រោកឡើងដេញវាទៅ» ។

ចៅមាណពភ្ញាក់ឡើងប្រែខ្លួនបន្តិច និយាយទៅកាន់ព្រាបសទាំងញ្ញមមីថា «ព្រាបសបងអើយ អរគុណបងណាស់ហើយ ដែលខំដាស់ឲ្យខ្ញុំភ្ញាក់ ។ ខ្ញុំភ្ញាក់យូរហើយ ខ្ញុំឮសូរញញូរដានដែក ខ្ញុំឃើញអ្នកស្រែប្រូតស្រូវ ឮមាត់ក្មេងរៀន - ឃើញគេទៅលក់ដូរ - ឃើញអាសត្វត្មាតបង្រែវាបុះដិតសួនច្បារខ្ញុំ តែខ្ញុំក្រោកមិនទាន់រួច ។ ខ្ញុំមានទុក្ខមួយធ្ងន់ណាស់ សង្កត់លើទ្រូងខ្ញុំ ។ ទុកនេះធ្ងន់លើសភ្នំព្រះសុមេរុទៅទៀត បងព្រាបស» ។

ព្រាបញីសឮមាណពនិយាយដូច្នោះ ក៏ឈប់សសិតស្លាបដើរមកជិតថ្ពាល់ចៅមាណពសួរថា: « ទុកអ្វីក៏ធ្ងន់ម៉្លេះចៅមាណព? ។ តើចៅប្រាប់យើងទាំងពីរឲ្យដឹងផងបានឬទេ ? យើងត្រេកអរណាស់បើសិនជាបានស្រង់ចៅឲ្យផុតពីទុក្ខនោះ» ។ ចៅមាណពងើបក្បាលឡើងបន្តិចពីស្មៅងាកមើលឆ្វេងស្តាំមិនឃើញអ្នកណាក៏អញ្ជើញព្រាបសទាំង ២ ទៅជិតហើយពណ៌នាសេចក្តីទុក្ខរបស់ខ្លួនយ៉ាងក្រៀមក្រំ: «ខ្ញុំជានិស្សិតអាភព្វ ។ មិនមែនអាភព្វខាងការសិក្សាទេ តែអាភព្វខាង

ស្នេហា ។ ទេវីនឹងខ្ញុំស្រឡាញ់គ្នាស្មើលេខ ។ ពេលរាត្រីស្ងាត់ក្រោមពន្លឺ
ព្រះច័ន្ទត្រចះត្រចង់ ទេវីនឹងខ្ញុំតែងបណ្ដើរគ្នាមកស្វែងរកសេចក្ដីសុខក្នុងទីនេះជា
រឿយៗ សួនច្បារនេះហើយជាស្ថានសួគ៌របស់ទេវីនឹងខ្ញុំ ។ ដើមកូឡាបនេះជាសាក្សី
នៃសេចក្ដីស្នេហារបស់យើងទាំងពីរ ។ យើងទាំងពីរសន្យាគ្នាយ៉ាងម៉ឺងម៉ាត់ថា
នឹងរួមសុខទុក្ខជាមួយគ្នារហូតអស់មួយជីវិត ។ ទេវីដឹងណាស់ទៅហើយថាខ្ញុំជា
និស្សិតក្រ តែទេវីថាសេចក្ដីក្រមិនមែនជាឧបសគ្គរបស់សេចក្ដីស្នេហាទេ ។ ឲ្យ
តែយើងស្រឡាញ់គ្នាស្មោះត្រង់នឹងគ្នា បាយទឹកអំបិលក៏ឆ្ងាញ់ណាស់ទៅហើយ ។
គ្មានឧបសគ្គៈអ្វីក្នុងលោកនេះមកបំបែកយើងទាំង២បានទេ ។ ស្ដាប់មើលចុះបង
ព្រាបស នេះហើយគឺទ្រឹស្ដីនៃសេចក្ដីស្នេហារបស់ទេវី ។ ខ្ញុំកាន់តែស្រឡាញ់
ទេវី, កាន់តែបូជាទេវីខ្លាំងឡើង ព្រោះទេវីជាស្ត្រីក្នុងឧត្ដមគតិរបស់ខ្ញុំ ដែលខ្ញុំ
ខំស្វះស្វែងរកមកយូរហើយ ។ ខ្ញុំបានជួបទេវីតែមួយខែប៉ុណ្ណោះ ស្រាប់តែបានទទួល
សំបុត្ររបស់ទេវីមួយច្បាប់សរសេរយ៉ាងខ្លីៗថា « យើងទាំងពីរជាគូកម្ម ។
ខ្ញុំមិនអាចរួមជីវិតជាមួយនឹងបងបាន ដោយខ្វះមុខខ្វះក្រោយទេ ។ ដូច្នោះយើង
ទាំងពីរប្ដូរអហោសិកម្មឲ្យគ្នានឹងគ្នាទៅចុះ » ។ កន្លះខែកន្លងមកទៀត
ទេវីក៏បានរៀបការ ជាមួយនឹងថៅកែម្នាក់ ។ រឿងនេះខ្ញុំស៊ើបដឹងថា
ទេវីត្រូវស្នេហា «គាប្រាក់» ។ ជួយមើលចុះបងព្រាបសអើយ ! ជុំវិញទឹកកកដ៏មហា

សមុទ្រហៅសែនជ្រៅ មនុស្សនៅវាស់ដឹងជំរៅ តែជំរៅទឹកចិត្តស្ត្រី មិនអាចវាស់ដឹងបានឡើយ ។ កង្ហាល់ដែលត្រូវខ្យល់វិលមិនដឹងប៉ុន្មានជុំក្នុងមួយម៉ោង តែចិត្តស្ត្រីវិលមិនដឹងជាប៉ុន្មានត្រឡប់ក្នុងមួយជុំ» ។

និយាយដល់ចំណុចនេះ ចៅមាណពឈ្លួលចេះឈឺចាប់ក្នុងដួងប្រមាត់ ព្រោះតែសរកាមទេពជ្រួលក់ថ្នាំពិស ដូច្នោះក៏ក្រញ៉ើតក្រញ៉ើមស្រែកយ៉ាងខ្លាំងថា «បងព្រាបស ខ្ញុំចង់បំផ្លាញសួនច្បារនេះឲ្យវិនាសទៅ ព្រោះឥឡូវសួននេះជាសួននរករបស់ខ្ញុំ ។ ខ្ញុំចង់តែកាប់គូឡាបនេះដុតចោលទៅ ព្រោះមិនមែនជាសាក្សីស័ក្តិសិទ្ធិនៃសេចក្តីស្នេហាសោះឡើយ ។ ខ្ញុំមិនអាចមានជីវិតនៅតទៅទៀតបានទេ ។ ខ្ញុំចង់តែដើរផឹកដើរលេងឲ្យវិនាសអន្តរាយជីវិតរបស់ខ្ញុំទៅ ។ ខ្ញុំត្រូវតែសម្លាប់ខ្លួនចោលទៅ ដើម្បីសំដែងឲ្យទេវីដឹងថា មាណពនេះស្មោះត្រង់ស្នេហាចំពោះទេវីប៉ុណ្ណោះ ។ ឱ! ទេវីប្អូនអើយ! ម្តេចឡើយក៏មិនអាណិតដល់សេចក្តីស្នេហារបស់យើងផង ។ ប្អូនទៅស្វែងរកសេចក្តីសុខចុះ បងនេះសុខចិត្តទទួលទុក្ខតែឯកឯង» ។

ចៅមាណពមើនិយាយតែម្នាក់ឯងដូចជាមនុស្សស្រវឹងឬឆ្កួត មាត់ណាក៏ឮតែស្នេហា ឮតែទេវី មិនដាច់ ។ និយាយមួយស្របក់ ចៅមាណពក៏យកដៃទាំងពីរបិទមុខយំសសឹកនៅនៀលក្រោមដើមគូឡាប ហាក់ដូចជាក្មេងតូចដែល

ត្រូវម្ដាយវាយ ៗ

ថាភ្លើងក្ដៅហើយ តែស្នេហានៅក្ដៅលើសភ្លើងទៅទៀត ៗ ចៅមាណព កំពុងត្រូវភ្លើងស្នេហាដុត មានថ្នាំអ្វីនឹងយកមករំងាប់ពិសនេះឲ្យត្រជាក់បាននុះ ?

បានឮសំដីនឹងឃើញអាកប្បកិរិយាចៅមាណពដូច្នោះ ព្រាបសទាំងពីរ ដកដង្ហើមធំនឹកសង្វេគដល់ចៅមាណពអក់តខ្លាំងពន់ពេកណាស់ ក៏លួងលោមចៅមាណពដោយវាចាពីរោះថា «មាណពចៅអើយ ! ចៅឈប់យំទៅ ៗ ចៅបោះបង់ចោលគំនិតគិតសម្លាប់ខ្លួនសិនទៅ ៗ យើងមករួមគ្នាប្រឹក្សារកហេតុផលដើម្បីស្រាយទុក្ខជាការប្រសើរជាង ៗ យើងព្រាបសមិនមែនតាំងខ្លួនធ្វើជាគ្រូចៅមាណពទេ ៗ ចៅមាណពក៏ជានិស្សិតជាន់ខ្ពស់ រមែងដឹងខុសត្រូវជាងអ្នកដែលអក់តខាងការសិក្សា ៗ ក្នុងពេលនេះយើងគ្រាន់តែមានយោបល់បន្តិចបន្តួចតាមសេចក្ដីសាមគ្គីរបស់យើងប៉ុណ្ណោះ ៗ ចៅមាណពចាំស្ដាប់ណា៎ ៗ កើតមកជាមនុស្សទាំងប្រុសស្រី រមែងគិតមិនផុតអំពីសេចក្ដីស្នេហាបានឡើយ ៗ ចៅមាណព ចៅស្នេហាទើបទើរស្នេហាចៅ នេះជារឿងធម្មតាតាមធម្មជាតិដែលយុវជនយុវនារីត្រូវតែមាន ៗ តែកម្មអ្វីដែលបណ្ដាលឲ្យសេចក្ដីស្នេហាបរិសុទ្ធរបស់ចៅមិនបានសម្រេចសមតាមបំណង ? កម្មនេះគឺមកអំពីស្នេហារបស់ចៅកើតចេញពីក្នុងសង្គមដែលពុករលួយ សង្គមដែលមនុស្សច្រើនតែនិយមបោក

បញ្ឆោតខ្លួនឯង–បោកបញ្ឆោតអ្នកដទៃ សង្គមប្រដែងគ្នា-ដណ្តើមគ្នាយ៉ាងអយុត្តិធម៌ ។ អ្នកណាខ្លាំងអ្នកនោះឈ្នះ អ្នកណាខ្សោយអ្នកនោះស្លាប់-...អ្ហូយ! ច្រើនណាស់ចៅមាណព ។ ចៅ.បើកភ្នែកឲ្យធំបន្តិចឡើងមើលឲ្យឃើញខ្លួនឯង ទើបចៅជ្រួតជ្រាបបានច្បាស់ជាង ។ ក្នុងសង្គមពុករលួយនេះ មិនមែនត្រឹមតែចៅម្នាក់ទេដែលទទួលទុក្ខបែបនេះ ។ នៅមានយុវជនយុវនារីរាប់ពាន់រាប់ហ្មឺនទៀត ដែលទទួលទុក្ខពីសង្គមដូចជាចៅឬលើសពីចៅទៅទៀត ។

តែមានអ្នកខ្លះឃើញសង្គមស្អុយរលួយ ក៏បណ្តោយខ្លួនឲ្យស្អុយរលួយទៅតាមសង្គម ។ គេគិតថា «គេម៉េចអញម៉េច» អ្នកទាំងនោះមានជីវិតដើម្បីធ្វើជាកញ្ជះឲ្យសង្គមស្អុយរលួយប៉ុណ្ណោះ ។

មានអ្នកខ្លះទៀត ឃើញសង្គមស្អុយរលួយណាស់ក៏កើតក្តីនឿយណាយធុញទ្រាន់រកវិធីយកតែខ្លួនឲ្យផុតម្នាក់ឯង ។ មិនគិតថាក្នុងសង្គមបែបនេះ ល្អម្នាក់ឯងទៅមិនរួចទេ ។ មិនយូរមិនឆាប់នឹងត្រូវសង្គមប្រទាញឲ្យចូលផ្លូវអាក្រក់ជាមិនខាន ។

មានអ្នកខ្លះទៀតធុញទ្រាន់ពេក ដោយត្រូវសង្គមធ្វើទុក្ខទោសជាខ្លាំង ក៏អស់អាល័យជីវិត ទៅសម្លាប់ខ្លួនឲ្យផុតពីសង្គមស្អុយនេះក៏សឹងតែមាន ។

ចៅមាណព ហេតុដែលទើប្រែក្រឡះ រលាស់ស្នេហាចោលចេញពីចៅ

គឺមកអំពីឥទ្ធិពលរបស់សង្គមរាំបណ្ដាលទៅដូច្នោះ ៗ ចៅមើលតែខ្លួនចៅក៏ជិនហើយ ៗ ចៅផ្ដាច់ពីសេចក្ដីស្នេហា គឺថាចៅទទួលទុក្ខ តែចៅត្រឡប់ជាទៅផឹកស្រា-លេងស្រី ដោយគិតថាដើម្បីបន្ធូរទុក្ខ ៗ តែការពិតគឺចៅយកទុក្ខមកលាងទុក្ខ ដូច្នោះទុក្ខក៏កាន់តែសង្កត់លើទ្រូងចៅធ្ងន់ឡើងៗ មិនតែប៉ុណ្ណោះ ចៅចង់សម្លាប់ខ្លួនចោលទៀត គឺថាចៅចង់រត់ឲ្យផុតពីទុក្ខដោយចៅស្ដាយទុក្ខទៅតាមខ្លួន ហើយចៅចោលទុក្ខរបស់ខ្លួនឲ្យអ្នកក្រោយទទួលយក ៗ សង្គមកាន់តែទទួលទុក្ខរបស់ចៅផ្សាយខ្លាំងឡើងថែមទៀត ៗ ចៅគិតដូច្នេះមកពីចៅធ្លាប់ឮធ្លាប់ឃើញ ធ្លាប់បានអាន ថាមានគេខ្លះធ្វើដូច្នេះ ៗ ចៅរស់នៅក្នុងសង្គមស្អុយរលួយ ចៅកាន់តែជួយបន្ថែមឲ្យសង្គមស្អុយរលួយ កាន់តែស្អុយរលួយខ្លាំងឡើងថែមទៀត ៗ

ចៅមាណព! ចៅជាយុវជន ជានិស្សិត ដែលជាអនាគតរុងរឿងរបស់ជាតិ របស់ប្រជាជន ៗ ជីវិតរបស់ចៅប្រៀបដូចជាកុឡាបកំពុងរីក ហើយចៅគិតនឹងក្ដិចយកទៅប្រលក់ក្នុងលាមក ឬយ៉ាងណា ? ៗ ជីវិតរបស់ចៅមាណពនៅមានប្រយោជន៍ច្រើនណាស់បើចេះប្រើឲ្យត្រូវ ៗ តែណាចៅមាណព! ជីវិតគឺអ្វី ? ជីវិតគឺការតស៊ូ ៗ តស៊ូចំពោះអ្វីដែលសង្កត់យើង អ្វីដែលធ្វើឲ្យយើងទុក្ខ យើងត្រូវតែតស៊ូ ៗ យើងដឹងថាសង្គមរាំស្អុយរលួយហើយ យើងមករួមគ្នា

ដុះលាស់ឲ្យស្អាតឡើងទើបប្រសើរជាងយើងរត់គេចពីសង្គម ។ បើប្រសិនជាអ្នកទាំងឡាយបានទទួលទុក្ខពីសង្គមហើយគេចចេញពីសង្គមគ្រប់ ៗ គ្នា តើសង្គមនេះ អស់ទុក្ខទេ? អ្នកនោះនឹងផុតពីទុក្ខទេ ? ។ ផ្ទុយទៅវិញទុក្ខកងសង្គមកាន់តែខ្លាំងឡើង ព្រោះអ្នកដែលមិនគប្បីចំពោះសង្គមស្អុយរលួយ កាន់តែត្រូវសង្គមស្អុយរលួយរាបក្ខបទ្វេមទុក្ខឲ្យទៀត ដោយគ្មានអ្នកណាហ៊ានរកាំងវា ។

មកចៅមាណព! យើងមករួមគ្នាកសាងសង្គមយើងឲ្យបានស្អាតបរិសុទ្ធឡើង ។ យើងកសាងតាមសមត្ថភាព តាមកម្លាំងរបស់យើង ។ យើងចាប់ផ្តើមកសាងតាំងឡូវទៅ ។ បើយើងមិនបានទទួលផលពីសង្គមដែលយើងកសាងក្នុងយើង ចៅយើង ជាតិយើងទាំងមូលនឹងបានទទួលផលជំនួសយើងជាមិនខាន,,។

ចៅមាណពឮព្រាបសនិយាយដូច្នោះ ក៏ភ្ញាក់ខ្លួនព្រើត ស្ទុះក្រោកឡើង ក្តាប់ដៃទាំងពីរ ខាំមាត់ក្រអឺត ស្រែកយ៉ាងខ្លាំងថា „ត្រូវហើយបងព្រាបស សង្គមនេះស្អុយរលួយណាស់ យើងរួមគ្នាកសាងសង្គមនេះឲ្យស្អាតបរិសុទ្ធឡើង ។

ឮសំរែកចៅមាណព ហ្វូងត្មាតចង្អែសដែលចុះជិតស្ទួនបក្សារ ចង់មកចោះចឹកចៅមាណពស៊ីដោយស្មានថា ចៅមាណពដេកស្លាប់ ក៏ស្ទុះហើរភ្លុលឡើងទៅលើអាកាសត្រូវខ្យល់បោករសាត់បាត់ឆ្ងាយទៅ ។ ឃើញដូច្នោះ

ព្រាបសញ្ជីនិយាយថា « នោះហ្ន៎ ! សត្វត្មាតដែលជាសញ្ញារបស់សង្គមស្អុយរលួយផ្អើលហើយតើ, តែវានៅពេលខ្លួនបង្អើសស្អុយទុកឲ្យបៅមាណពលាងសំអាតនៅតាមក្រោយ ។

(( –០ប ប់០– ))

# សៀវភៅដែលគួរអាន

មុននឹងសរសេរតទៅទៀត យើងសូមអភ័យទោសដល់អ្នកនិពន្ធទាំងឡាយ គំនិតយើងដែលសរសេរក្នុងអត្ថបទនេះ គឺមិនមែនបង់ផ្សាយសៀវភៅរបស់អ្នកណាៗទេ យើងសរសេរនេះគឺនៅក្នុងស្មារតីទ្រទ្រង់វប្បធម៌ខ្មែរយើងតែប៉ុណ្ណោះ។

-ចំពោះប្រលោមលោកក្នុង១ខែ ៗ គេឃើញមានរឿងផ្សេងៗជានិច្ច យើងមិនអាចដឹងថារឿងណាចេញពីខែណាទេ បើដឹងៗបានខ្លះដោយពុំគ្រប់គ្រាន់ដូចជា:

- នារីកំសត់
- ល្អាងទឹកស្លិត
- ស៊ឹមអ្នបរឡាន
- ទឹកភ្នែកនារី ។ល។
- សៀវភៅសិល្ប: សៀវភៅនេះក៏កាន់តែមានច្រើនណាស់ដែរដូចជា
- រៀមច្បងយើង
- ថ្នរកំ
- កញ្ញាចរិយា ។ល។

- ខ្មែរភ្ញាក់រលឹក
- វិបត្តិស្នេហា
- សៀវភៅសិក្សា មានដូចតទៅនេះ
- ប្រវត្តិអក្សរសាស្ត្រខ្មែរ
- អត្ថាធិប្បាយរឿងព្រេងខ្មែរ
- លទ្ធិប្រជាធិបតេយ្យ
- ស្ត្រីនិងទារក
- វេជ្ជវិជ្ជានិងអនាម័យ

ឯសៀវភៅសំរាប់សិស្សក្តី អ្នករាជការក្តី ក៏មានច្រើនដែរ យើងមិនរាប់រៀបទេសៀវភៅអស់នោះ ព្រោះថាយើងម្នាក់ៗក្នុងសម័យនេះត្រូវតែរៀនភាសាខ្មែរឲ្យហ្មត់ចត់ ។

ដូច្នោះយើងឃើញថាអ្នកអានសព្វថ្ងៃមិនខ្វះសៀវភៅទេគ្រាន់តែពិបាករើសៗ ក្នុងការរើសនេះយើងអាចជួយយោបល់បានដូចនេះ ចំពោះអ្នកណាដែលចង់អណ្តែតអណ្តូងក្នុងអន្លង់ស្នេហា សូមឲ្យមើលប្រលោមលោកចុះព្រោះ ខ្លឹមសារច្រើនសង្កត់ទៅលើតែមនោសញ្ចេតនានៃស្នេហាតែប៉ុណ្ណោះ ។

ចំពោះអ្នកចង់ដឹងការរស់នៅដ៏ជាក់ស្តែងពីកម្មករពីអ្នករាជការខ្លះវិញ សូមឲ្យ

អាន ។ «សុំអ្នកបរឡាន» ។

ចំពោះអ្នកចង់ដឹងពីចារណាពិគំនិតអ្វីមួយៗ សូមអានសៀវភៅសិស្សសិល្បៈ ។

ចំពោះអ្នកចង់ចេះចង់ដឹងពីដំណេះទូទៅវិញ សូមឲ្យអានសៀវភៅសិក្សា ។

នេះជាការណែនាំអ្នកក្នុងពេលរើសរកសៀវភៅមកអានទេ ។ យើងធ្វើនេះជាការសង្ខេបណាស់ពីព្រោះទស្សនាវដ្ដីទើបនឹងកើតឡើង ឯសៀវភៅវិញមានច្រើនណាស់ទៅហើយ ។ យើងសង្ឃឹមថាលេខក្រោយៗយើងនឹងធ្វើអត្ថាធិប្បាយឲ្យល្អិតល្អន់បន្តិច ។ ក្នុងការធ្វើអត្ថាធិប្បាយលើប្រលោមលោកលើសៀវភៅផ្សេងៗទៅថ្ងៃក្រោយ យើងសង្ឃឹមថាសមាគមអ្នកនិពន្ធខ្មែរ នឹងជួយបំភ្លឺយើងនៅក្នុងរឿងនេះផង ។

—១០០—

តម្លៃ ១០ រៀល

រោងពុម្ព យសោភណ្ឌ